## ១~ មហាបរិនិព្វានសុត្តំ ១៦/២៥៦

ទហរាបិ ច យេ វុឌ្ឍា យេ ពាលា យេ ច បណ្ឌិតា
អឌ្ឍា ចេវ ទលិទ្ទា ច សព្វេ មច្ចុបរាយនា ។

យថាបិ កុម្ភការស្ស កតំ មត្តិកភាជនំ
ខុទ្ទកញ្ច មហន្តញ្ច យញ្ច បក្កំ យញ្ច អាមកំ
សព្វំ ភេទបរិយន្តំ ឯវំ មច្ចាន ជីវិតំ ។





## **១ –មហាបរិនិព្វានសូត្រ** បិដកលេខ ១៦, ទំព័រ ២៥៦

ពួកជនណាៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់នៅពីខាងមុខ ។

ភាជន៍ដី ដែលស្មូនឆ្នាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត យ៉ាងណាមិញ ជីវិតរបស់សត្វទាំងឡាយក៏យ៉ាងនោះដែរ ។

## ២. អង្គុលិមាលសុត្តំ ២៤/៤៣៤

យោ ច បុព្វេ បមជ្ជិត្វា  បច្ឆា សោ នប្បមជ្ជតិ
សោមំ លោកំ បភាសេតិ អព្ភាមុត្តោវ ចន្ទិមា ។

យស្ស បាបំ កតំ កម្មំ  កុសលេន បិធីយតិ
សោមំ លោកំ បភាសេតិ អព្ភាមុត្តោវ ចន្ទិមា ។

យោ ហវេ ទហរោ ភិក្ខុ  យុញ្ជតិ ពុទ្ធសាសនេ
សោមំ លោកំ បភាសេតិ អព្ភាមុត្តោវ ចន្ទិមា ។





## ២ – អង្គុលិមាលសូត្រ បិដកលេខ ២៤, ទំព័រ ៤៣៤

បុគ្គលណា ធ្វេសប្រហែសក្នុងកាលមុន ដល់កាលជាខាងក្រោយមក បុគ្គលនោះមិនធ្វេសប្រហែសវិញ អ្នកនោះឯងឈ្មោះថា ញុំាងលោកនេះឱ្យភ្លឺច្បាស់ ដូចព្រះចន្ទផុតស្រឡះចាកពពក ។

បាបកម្ម ដែលបុគ្គលណាធ្វើហើយ តែបុគ្គលនោះត្រឡប់ជាបិទនូវបាបកម្មនោះបាន ដោយសារកុសល អ្នកនោះឯងឈ្មោះថា ញុំាងលោកនេះឱ្យភ្លឺច្បាស់ ដូចព្រះចន្ទផុតស្រឡះចាកពពក ។

ភិក្ខុណា នៅកំលោះ បានប្រកបព្យាយាមក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះឯងឈ្មោះថា ញុំាងលោកនេះឱ្យភ្លឺច្បាស់ ដូចព្រះចន្ទផុតស្រឡះចាកពពក ។

## ៣~ វាសេដ្ឋសុត្តំ ២៥/២១៥-២២៣

វារិបោក្ខរបត្តេវ អារគ្គេរិវ សាសបោ
យោ ន លិម្បតិ កាមេសុ តមហំ ព្រូមិ ព្រាហ្មណំ។

កម្មុនា វត្តតិ លោកោ កម្មុនា វត្តតិ បជា
កម្មនិ ពន្ធនា សត្តា រថស្សាណីវ យាយតោ។





## ៣ – វាសេដ្ឋសូត្រ បិដក ២៥, ទំព័រ ២១៥-២២៣

បុគ្គលណាមិនជាប់ក្នុងកាមទាំងឡាយ ដូចទឹកមិនជាប់លើស្លឹកឈូក ឬដូចគ្រាប់ស្ពៃមិនជាប់លើចុងនៃដែកស្រួច តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ។

លោកតែងប្រព្រឹត្តទៅតាមកម្ម ប្រជាជនតែងប្រព្រឹត្តទៅតាមកម្ម សត្វទាំងឡាយជាប់នៅក្នុងកម្ម ទើបប្រព្រឹត្តទៅបាន ដូចរទេះដែលមានភ្លៅ ទើបបរទៅបាន[១] ដូច្នោះឯង ។

១-ពាក្យថា **លោកោ** , **បជា** , **សត្តា** ទាំង ៣ ពាក្យនេះផ្សេងគ្នាតែព្យញ្ជនៈ ។ ក្នុងបទទី ១ បដិសេធមហាព្រហ្មជាអ្នកសាងលោក ។ បទទី ២ សម្តែងអំពីអំណាចកម្មទាំងអតីតកម្ម ទាំងបច្ចុប្បន្នកម្ម ។ បទទី ៣ ចំណងកម្ម ។ បទទី ៤ ឧបមា ។ អដ្ឋកថា ។

## ៤. អច្ឆរាសុត្តំ ២៩/៨៣

ឧជុកោ នាម សោ មគ្គោ  អភយា នាម សា ទិសា
រថោ អកូជនោ នាម  ធម្មចក្កេហិ សំយុត្តោ។

ហិរី តស្ស អបាលម្ពោ  សតស្ស បរិវារណំ
ធម្មាហំ សារថឹ ព្រូមិ  សម្មាទិដ្ឋិបុរេជវំ ។

យស្ស ឯកទិសំ យានំ  ឥត្ថិយា បុរិសស្ស វា
ស វេ ឯតេន យានេន  និព្វានស្សេវ សន្តិកេ ។





## ៤- អច្ឆរាសូត្រ បិដកលេខ ២៩ , ទំព័រ ៨៣

ផ្លូវនោះ ឈ្មោះថាផ្លូវត្រង់ ទិសនោះឈ្មោះថាទិសមិនមានភ័យ រថឈ្មោះថារថមិនឮសូរ ប្រកបដោយកង់គឺសេចក្ដីព្យាយាម ។

ការខ្មាសបាប ជាទ្រពងរទេះ ( សម្រាប់ទប់អ្នកជិះកុំឱ្យធ្លាក់) សតិ ជាគ្រោះ ( សម្រាប់រារាំងសរគឺកិលេស ) តថាគតពោលថាធម៌គឺលោកុត្តរមគ្គជាសារថី មានសម្មា-ទិដ្ឋិស្ទុះទៅមុន ។

ជនណា ទោះស្រីឬប្រុស បានយានបែបនោះហើយ ជននោះឯង នឹងដល់នូវទីជិតនៃព្រះនិព្វាន ដោយយាននោះឯង ពុំខានឡើយ ។

## ៥_ ឥស្សត្តសុត្តំ ២៩/២៧២

យថាបិ មេឃោ ថនយំ វិជ្ជុមាលី សតក្កកុ
ថលំ និន្នញ្ច បូរេតិ អភិវស្សំ វសុន្ធរំ ។
តថេវ សទ្ធោ សុតវា អភិសង្ខច្ច ភោជនំ
វណិព្វកេ តប្បយតិ អន្នបានេន បណ្ឌិតោ
អនុមោទមានោ បកិរេតិ ទេថ ទេថាតិ ភាសតិ ។
តញ្ហិស្ស គជ្ជិតំ ហោតិ ទេវស្សេវ បវស្សតោ
សា បុញ្ញធារា វិបុលា ទាតារំ អភិវស្សតីតិ ។





## ៥- ឥស្សត្តសូត្រ បិដកលេខ ២៩, ទំព័រ ២៧២

មហាមេឃគ្រហឹម របៀបនៃផ្លេកបន្ទោរ មានកំពូលរាប់រយ ភ្លៀងបង្អុរចុះលើផែនដី ញុំាងទីទួលនិងទីទាបឱ្យពេញបាន យ៉ាងណាមិញ ។ បុគ្គលជាបណ្ឌិត មានសទ្ធា ស្តាប់ធម៌បានចេះដឹងហើយ តាក់តែងនូវភោជនឱ្យដល់ពួកវណិព្វក[១] បានឆ្អែត ដោយបាយនិងទឹក ក៏យ៉ាងនោះដែរ ។ បុគ្គលមានចិត្តត្រេកអរ ចែកចាយទ្រព្យឱ្យជាទាន ហើយពោលថា អ្នកទាំងឡាយចូរឱ្យទាន អ្នកទាំងឡាយចូរឱ្យទាន ដូច្នេះឯង ។

ពាក្យនោះ បុគ្គលនោះបានបញ្ចេញឱ្យលាន់ឮហើយ ( ដូចផ្គរលាន់ពេលភ្លៀង ) ធារទឹកគឺបុណ្យដ៏ធំទូលាយនោះនឹងបង្អុរចុះលើបុគ្គលអ្នកឱ្យ ដូចជាមហាមេឃដែលបង្អុរភ្លៀងមកលើផែនដីដែរ ។

១_ស្មូម,សូមបានហើយពោលសរសើរ ឱ្យពរដល់ម្ចាស់ទាន ។

## ៦- សេលាសុត្តំ ៣០/១៩

នយិទំ បកតំ ពិម្ពំ    នយិទំ បកតំ អឃំ
ហេតុំ បដិច្ច សម្ភូតំ    ហេតុភង្គា និរុជ្ឈតិ ។

យថាបិ អញ្ញតរំ ពីជំ    ខេត្តេ វុត្តំ វិរូហតិ
បឋវីរសញ្ច អាគម្ម    សិនេហញ្ច តទូភយំ ។
ឯវំ ខន្ធា ច ធាតុយោ    ឆ ច អាយតនា ឥមេ
ហេតុំ បដិច្ច សម្ភូតា    ហេតុភង្គា និរុជ្ឈរេ ។





## ៦- សេលាសូត្រ បិដកលេខ ៣០ , ទំព័រ ១៩

ពុម្ពគឺអត្តភាពនេះ ឥតមានអ្នកណាតាក់តែងទេ អឃៈគឺអត្តភាពដែលជាទីតាំងនៃសេចក្ដីទុក្ខនេះ ឥតមានអ្នកណាធ្វើទេ កើតឡើងបាន ព្រោះអាស្រ័យហេតុ រលត់ទៅវិញ ព្រោះបែកធ្លាយនៃហេតុ ។

ដូចជាពូជឯណាមួយ ដែលគេសាបព្រោះក្នុងស្រែ រមែងដុះឡើងបាន ព្រោះអាស្រ័យនូវធម្មជាតិ ២ យ៉ាង គឺរសនៃផែនដី ១ , ជ័រនៃពូជនោះ ១ យ៉ាងណាមិញ ធម៌ទាំងនេះគឺ ខន្ធ ធាតុ និងអាយតនៈ ៦ កើតឡើងបាន ព្រោះអាស្រ័យហេតុ រលត់ទៅវិញ ព្រោះការបែកធ្លាយនៃហេតុ យ៉ាងនោះឯង ។

## ៧. វជិរាសុត្តំ ៣០/២២

កឹ នុ សត្តោតិ បច្ចេតិ  មារ ទិដ្ឋិគតំ នុ តេ
សុទ្ធសង្ខារបុញ្ជោយំ  នយិធ សត្តុបលព្ភតិ ។
យថា ហិ អង្គសម្ភារា  ហោតិ សទ្ទោ រថោ ឥតិ
ឯវំ ខន្ធេសុ សន្តេសុ  ហោតិ សត្តោតិ សម្មុតិ។

ទុក្ខមេវ ហិ សម្ភោតិ  ទុក្ខំ តិដ្ឋតិ វេតិ ច
នាញ្ញត្រ ទុក្ខា សម្ភោតិ  នាញ្ញត្រ ទុក្ខា និរុជ្ឈតីតិ។





## ៧ - វជិរាសូត្រ បិដកលេខ ៣០ , ទំព័រ ២២

ម្នាលមារ ទិដ្ឋិរបស់អ្នកយល់ថា សត្វមែនឬ នេះជាគំនរនៃសង្ខារសុទ្ធទេ អ្នករកសត្វមិនឃើញឡើយ ។

ដូចសព្ទដែលហៅថា « រថ » ដូច្នេះ កើតឡើងបាន ព្រោះបរិបូណ៌ដោយអង្គ ( មានកង់ ទូក ប្រែកជាដើម ) យ៉ាងណាមិញ កាលបើខន្ធមានហើយ ការសន្មតថា « សត្វ » ដូច្នេះ ក៏មាន យ៉ាងនោះឯង ។

តាមពិត មានតែទុក្ខទេដែលកើតឡើង មានតែទុក្ខទេដែលតាំងនៅ និងមានតែទុក្ខទេដែលប្រែប្រួលទៅ ក្រៅពីទុក្ខ មិនមានអ្វីកើត ក្រៅពីទុក្ខ មិនមានអ្វីរលត់ឡើយ ។

## ៨. សតាឃារទ្ធសុត្តំ ៣២/៣៩

សំសគ្គា វនថោ ជាតោ អសំសគ្គេន ឆិជ្ជតិ
បរិត្តំ ទារុមារុយ្ហ យថា សីទេ មហណ្ណវេ
ឯវំ កុសីតមាគម្ម សាធុជីវីបិ សីទតិ
តស្មា តំ បរិវជ្ជេយ្យ កុសីតំ ហីនវីរិយំ
បវិវិត្តេហិ អរិយេហិ បហិតត្តេហិ ឈាយិភិ
និច្ចំ អារទ្ធវីរិយេហិ បណ្ឌិតេហិ សហាវសេតិ។





## ៨- សតាឃារទ្ធសូត្រ បិដកលេខ ៣២ , ទំព័រ ៣៩

ព្រៃគឺកិលេសដុះឡើងព្រោះការច្រឡូកច្រឡំ ព្រៃគឺកិលេសដាច់ទៅព្រោះការមិនច្រឡូកច្រឡំ ។ បុគ្គលតោងឈើតូច មុខជាលិចចុះក្នុងអន្លង់ធំ យ៉ាងណាមិញ បុគ្គលទោះបីចិញ្ចឹមជីវិតដោយស្រួល តែអាស្រ័យនឹងជនខ្ជិលច្រអូស រមែងលិចចុះទៅ យ៉ាងនោះឯង ។ ព្រោះហេតុដូច្នោះ បុគ្គលគប្បីវៀរស្រឡះចាកបុគ្គលខ្ជិលច្រអូស ជាអ្នកមានសេចក្តីព្យាយាមថោកទាបនោះចេញ គប្បីនៅជាមួយនឹងជនជាបណ្ឌិត ជាអ្នកស្ងប់ស្ងាត់ ជាអ្នកប្រសើរ ជាអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជាអ្នកមានឈាន និងជាអ្នកប្រារព្ធនូវសេចក្តីព្យាយាមជានិច្ច ។

## ៩. ផេណបិណ្ឌសុត្តំ ៣៣/៣២៥-៣២៦

ផេណបិណ្ឌូបមំ រូបំ     វេទនា បុព្វុឡូបមា
មរីចិកូបមា សញ្ញា     សង្ខារា កទលូបមា
មាយូបមញ្ច វិញ្ញាណំ     ទេសិតាទិច្ចពន្ធុនា ។

យថា យថា និជ្ឈាយតិ យោនិសោ ឧបបរិក្ខតិ
រិត្តកំ តុច្ឆកំ ហោតិ     យោ នំ បស្សតិ យោនិសោ។

ឯតាទិសាយំ សន្តានោ   មាយាយំ ពាលលាបិនី
វធកោ ឯកោ អក្ខាតោ សារោ ឯត្ថ ន វិជ្ជតិ ។





## ៩ - ផេណបិណ្ឌសូត្រ បិដក ៣៣,ទំព័រ ៣២៥-៣២៦

ព្រះពុទ្ធ មានផៅពង្សដូចជាព្រះអាទិត្យ សម្តែងហើយថា រូបដូចជាដុំនៃពពុះទឹក វេទនាដូចជាក្រពេញទឹក សញ្ញាដូចជាថ្ងៃបណ្តើរកូន សង្ខារទាំងឡាយដូចជាដើមចេក វិញ្ញាណដូចជាកលមាយា ។

បុគ្គល ក្រឡេកមើលដោយប្រការណា១ រមែងពិចារណាដោយឧបាយ ដោយប្រការនោះ១ បុគ្គលណាឃើញនូវខន្ធបញ្ចកៈនោះដោយឧបាយ ខន្ធបញ្ចកៈនោះជារបស់សោះសូន្យទទេ តែងប្រាកដ (ដល់បុគ្គលនោះ )។

ធម៌ជាតំណ[១] នេះ ប្រាកដដូច្នេះឯង កិច្ចកលនេះជាគ្រឿងប្រលោមនូវជនពាល ខន្ធនេះអ្នកប្រាជ្ញពោលហើយថា ជាពេជ្ឈឃាតមួយ ឯខ្លឹមរមែងមិនមានក្នុងខន្ធនេះឡើយ ។

១_ធម៌ជាបវេណី ។

## ១០~ ទុតិយំ ជនសុត្តំ ៤១/១៣៥-១៣៦

អាទិត្តស្មឹ អគារស្មឹ យំ នីហរតិ ភាជនំ
តំ តស្ស ហោតិ អត្ថាយ នោ ច យំ តត្ថ ឌយ្ហតិ
ឯវមាទិត្តកោ លោកោ ជរាយ មរណេន ច
នីហរេថេវ ទានេន ទិន្នំ ហោតិ សុនីហតំ ។

យោធ កាយេន សញ្ញមោ
វាចាយ ឧទ ចេតសា
តំ តស្ស បេតស្ស សុខាយ ហោតិ
យំ ជីវមានោ បករោតិ បុញ្ញានិ ។





## **១០ - ជនសូត្រ ទី ២** បិដក ៤១,ទំព័រ ១៣៥-១៣៦

កាលបើផ្ទះ ត្រូវភ្លើងឆេះ ជនម្ចាស់ផ្ទះបានជញ្ជូនភាជន៍ណាចេញផុត ( អំពីផ្ទះ ) ឬទ្រព្យណាក្នុងផ្ទះនោះ (ដែលគេជញ្ជូនចេញហើយ) ភ្លើងឆេះមិនបាន ទ្រព្យនោះ រមែងបានជាប្រយោជន៍របស់គេ យ៉ាងណា សត្វលោកដែលត្រូវភ្លើងគឺជរា និងមរណៈឆាបឆេះ គួរប្រញាប់ជញ្ជូនទ្រព្យចេញឱ្យផុត (អំពីផ្ទះគឺរាងកាយ) ដោយការឱ្យទាន ( ព្រោះថា ) ទានដែលគេឱ្យហើយ ឈ្មោះថាបានជញ្ជូនដោយល្អ ក៏យ៉ាងនោះដែរ ។

ការសង្រួមដោយកាយ វាចា ចិត្តណា ពីឥឡូវនេះទៅ បុណ្យ (ដែលកើតមកអំពីការសង្រួម) នោះ រមែងបង្កើតសុខឱ្យដល់បុគ្គលដែលទៅកាន់បរលោកហើយនោះ ហេតុនោះ កាលបើបុគ្គលរស់នៅ គួរតែធ្វើបុណ្យ ។

## សុត្តន្តបិដកេ អង្គុត្តរនិកាយស្ស ចតុក្កនិបាតោ

### ១១_បឋមំ បុញ្ញាភិសន្ទសុត្តំ ៤២/១៣៦

មហោទធឹ អបរិមិតំ មហាសរំ
ពហុភេរវំ រតនគណានមាលយំ
នជ្ជោ យថា មច្ឆគណសង្ឃសេវិតា
បុថូ សវន្តី ឧបយន្តិ សាគរំ ។
ឯវំ នរំ អន្នទបានវត្ថទំ
សេយ្យានិសជ្ជត្ថរណស្ស ទាយកំ
បុញ្ញស្ស ធារា ឧបយន្តិ បណ្ឌិតំ
នជ្ជោ យថា វារិវហាវ សាគរន្តិ ។



## សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត

### ១១ –បុញ្ញាភិសន្ទសូត្រ ទី ១ បិដក ៤២ , ទំព័រ ១៣៦

ទន្លេទាំងឡាយដ៏ច្រើន ជាទីនៅអាស្រ័យនៃពួកត្រីរមែងហូរចុះទៅកាន់សាគរ ។ សាគរជាអន្លង់ទឹកធំ ដែលបុគ្គលប្រមាណមិនបាន ជាស្រះធំ ប្រកបដោយអារម្មណ៍គួរឱ្យស្ញប់ស្ញែងដ៏ក្រៃលែង ជាទីកើតនៃរតនវត្ថុទាំងឡាយ យ៉ាងណាមិញ ធារនៃបុណ្យ រមែងប្រព្រឹត្តហូរទៅកាន់ជនដែលជាបណ្ឌិតអ្នកឱ្យនូវបាយទឹក សំពត់ ទីដេក ទីអង្គុយ និងគ្រឿងកម្រាល ដូចជាស្ទឹងទន្លេទាំងឡាយដែលហូរទៅកាន់សាគរ យ៉ាងនោះឯង ។

សុត្តន្តបិដកេ អង្គុត្តរនិកាយស្ស បញ្ចកនិបាតោ

## ១២- សុមនសុត្តំ ៤៤/៦៧

យថាបិ ចន្ទោ វិមលោ គច្ឆំ អាកាសធាតុយា
សព្វេ តារគណេ លោកេ អាភាយ អតិរោចតិ
តថេវ សីលសម្បន្នោ សទ្ធោ បុរិសបុគ្គលោ
សព្វេ មច្ឆរិនោ លោកេ ចាគេន អតិរោចតិ ។

## កិន្ទទសុត្តំ ២៩/៨០

អន្នទោ ពលទោ ហោតិ វត្ថទោ ហោតិ វណ្ណទោ
យានទោ សុខទោ ហោតិ ទីបទោ ហោតិ ចក្ខុទោ។
សោ ច សព្វទទោ ហោតិ យោ ទទាតិ ឧបស្សយំ
អមតន្ទទោ ច សោ ហោតិ យោ ធម្មមនុសាសតីតិ។



សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត

## ១២ - សុមនសូត្រ បិដកលេខ ៤៤ , ទំព័រ ៦៧

ព្រះចន្ទមិនមានមន្ទិល កាលចរទៅតាមអាកាស រមែងរុងរឿងលើសជាងពួកផ្កាយទាំងអស់នៅក្នុងអាកាស ដោយពន្លឺ យ៉ាងណាមិញ បុគ្គលជាសប្បុរសដែលជាអ្នកមាននូវសទ្ធា បរិបូណ៌ដោយសីល រមែងរុងរឿងជាងពួកបុគ្គលកំណាញ់ទាំងអស់ក្នុងលោក ដោយចាគៈ ក៏យ៉ាងនោះដែរ ។

## កិន្ទទសូត្រ បិដកលេខ ២៩ , ទំព័រ ៨០

បុគ្គល ឱ្យបាយ ឈ្មោះថាឱ្យកម្លាំង ឱ្យសំពត់ ឈ្មោះថាឱ្យពណ៌សម្បុរ ឱ្យយានជំនិះ ឈ្មោះថាឱ្យសេចក្ដីសុខ ឱ្យប្រទីប ឈ្មោះថាឱ្យចក្ខុ ។

បុគ្គលណា ឱ្យទីនៅអាស្រ័យ បុគ្គលនោះ ឈ្មោះថាឱ្យវត្ថុគ្រប់យ៉ាង បុគ្គលណា ប្រៀនប្រដៅធម៌ បុគ្គលនោះ ឈ្មោះថាឱ្យព្រះនិព្វាន ។

## ១៣_ សទ្ធានិសំសសុត្តំ ៤៤/៨៤

សាខាបត្តផលូបេតោ ខន្ធិមាវ មហាទុមោ
មូលវា ផលសម្បន្នោ បតិដ្ឋា ហោតិ បក្ខិនំ ។
មនោរមេ អាយតនេ សេវន្តិ នំ វិហង្គមា
ឆាយំ ឆាយត្ថិកា យន្តិ ផលត្ថា ផលភោជិនោ
តថេវ សីលសម្បន្នំ សទ្ធំ បុរិសបុគ្គលំ
និវាតវុត្តឹ អត្ថទ្ធំ សុរតំ សខិលំ មុទុំ ។





## ១៣ – សទ្ធានិសំសសូត្រ បិដកលេខ ៤៤,ទំព័រ ៨៤

ដើមឈើធំ បរិបូណ៌ដោយមែក ស្លឹក ផ្លែ មានដើម និងឫសមាំទាំ និងមានផ្លែបន្តជានិច្ច រមែងជាទីពឹងពំនាក់របស់សត្វបក្សីទាំងឡាយ ។ ពួកសត្វតែងអាស្រ័យនឹងដើមឈើនោះ ដែលនៅក្នុងព្រៃរំលោង ជាទីរីករាយនៃចិត្ត ពួកសត្វដែលត្រូវការម្លប់ក៏ជ្រកម្លប់ ពួកសត្វដែលត្រូវការផ្លែ ក៏បរិភោគផ្លែ យ៉ាងណាមិញ បុគ្គលជាសប្បុរសដែលជាអ្នកមាននូវសទ្ធា បរិបូណ៌ដោយសីល ប្រព្រឹត្តឱនលំទោន មិនរឹងរូស ស្លូតត្រង់ ទន់ភ្លន់ ក៏ប្រាកដដូចជាដើមឈើ រមែងជាទីរាប់អាននៃពពួកជនដូច្នោះដែរ ។

## ១៤. សាលសុត្តំ ៤៤/៨៧

យថា ហិ បព្វតោ សេលោ អរញ្ញស្មិំ ព្រហាវនេ
តំ រុក្ខា ឧបនិស្សាយ វឌ្ឍន្តេ តេ វនប្បតី
តថេវ សីលសម្បន្នំ សទ្ធំ កុលបុត្តំ ឥធ
ឧបនិស្សាយ វឌ្ឍន្តិ បុត្តទារា ច ពន្ធវា
អមច្ចា ញាតិសង្ឃា ច យេ ចស្ស អនុជីវិនោ
ត្យស្ស សីលវតោ សីលំ ចាគំ សុចរិតានិ ច
បស្សមានានុកុព្វន្តិ យេ ភវន្តិ វិចក្ខណា។





## ១៤ - សាលសូត្រ បិដកលេខ ៤៤ , ទំព័រ ៨៧

ដើមឈើទាំងឡាយ អាស្រ័យនឹងភ្នំថ្មក្នុងដងព្រៃធំ រមែងចម្រើនឡើងជាដើមឈើធំ ព្រោះអាស្រ័យភ្នំថ្មនោះឯង យ៉ាងណាមិញ កូនប្រពន្ធទាំងឡាយ ផៅពង្សទាំងឡាយ អាមាត្យទាំងឡាយ ពួកញាតិទាំងឡាយ និងពួកជនអ្នកចិញ្ចឹមជីវិត ដោយសារបុគ្គលនោះ រមែងចម្រើនឡើង ព្រោះអាស្រ័យនឹងកុលបុត្រអ្នកមានសទ្ធាបរិបូណ៌ដោយសីលក្នុងលោកនេះ ។ ពួកជនមានកូននិងប្រពន្ធជាដើមនោះ ឃើញសីលផង ចាគៈផង និងសុចរិតទាំងឡាយផង របស់កុលបុត្រ អ្នកមានសីលនោះហើយ រមែងធ្វើតាម ក៏យ៉ាងនោះដែរ ។

## ១៥~ រតនសុត្តំ ៥២/៨-១០

យថិន្ទខីលោ បឋវឹ សិតោ សិយា
ចតុព្ភិ វាតេភិ អសម្បកម្បិយោ
តថូបមំ សប្បុរិសំ វទាមិ
យោ អរិយសច្ចានិ អវេច្ច បស្សតិ។
វនប្បគុម្ពេ យថា ផុស្សិតគ្គេ
គិម្ហានមាសេ បឋមស្មឹ គិម្ហេ
តថូបមំ ធម្មវរំ អទេសយិ
និព្វានគាមឹ បរមំ ហិតាយ ។





## ១៥- រតនសូត្រ បិដកលេខ ៥២ , ទំព័រ ៨-១០

សសរគោល ដែលគេបោះភ្ជាប់នឹងផែនដី ជារបស់មិនកម្រើកញាប់ញ័រដោយខ្យល់ព្យុះ ដែលបក់មកអំពីទិសទាំង ៤ យ៉ាងណាមិញ អ្នកណាពិចារណាឃើញនូវអរិយ-សច្ចទាំងឡាយ តថាគតហៅអ្នកនោះ ថាជាសប្បុរស (មិនញាប់ញ័រដោយលោកធម៌ទាំងឡាយ ) ដូចជាសសរគោលដូច្នោះឯង ។

គុម្ពឈើក្នុងព្រៃ មានត្រួយលូតលាស់ក្នុងខាងដើមនៃគិម្ហរដូវ គឺខែក្តៅ យ៉ាងណាមិញ ព្រះពុទ្ធទ្រង់បានត្រាស់សម្តែងហើយនូវធម៌ដ៏ប្រសើរ ជាធម៌អាចញ៉ាំងសត្វទាំងឡាយ ឱ្យដល់នូវព្រះនិព្វាន ដើម្បីប្រយោជន៍ដ៏ឧត្តម ដូចជាគុម្ពឈើក្នុងព្រៃ ដូច្នោះឯង ។

## ១៦~ តិរោកុឌ្ឌកណ្ឌំ ៥២/១៤

ឧន្នតេ ឧទកំ វុដ្ឋំ យថា និន្នំ បវត្តតិ
ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ ។

យថា វារិវហា បូរា បរិបូរេន្តិ សាគរំ
ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ ។

អទាសិ មេ អកាសិ មេ ញាតិមិត្តា សខា ច មេ
បេតានំ ទក្ខិណំ ទជ្ជា បុព្វេ កតមនុស្សរំ ។





## ១៦ – តិរោកុឌ្ឌកណ្ឌ បិដកលេខ ៥២ , ទំព័រ ១៤

ទឹកភ្លៀង ធ្លាក់ចុះលើទីទួល រមែងហូរទៅកាន់ទីទាប ដូចម្ដេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ រមែងសម្រេចផល ដល់ប្រេតទាំងឡាយ ដូច្នោះដែរ ។

ផ្លូវទឹកមានទន្លេ និងស្ទឹងជាដើម ដ៏ពេញ រមែងញ៉ាំងសាគរឱ្យពេញប្រៀប ដូចម្ដេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ រមែងសម្រេចផល ដល់ប្រេតទាំងឡាយ ដូច្នោះដែរ ។

បុគ្គល កាលរលឹកឃើញនូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួនក្នុងកាលមុនថា អ្នកនេះបានឱ្យរបស់នេះដល់អញ ជនទាំងឡាយនោះ ជាញាតិមិត្ត ជាសម្លាញ់របស់អញដូច្នេះហើយ គួរឱ្យនូវទក្ខិណាទាន ចំពោះប្រេតទាំងឡាយ ។

## ១៧- យមកវគ្គោ ៥២/២២

សុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ
ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវីរិយំ
តំ វេ បសហតី មារោ វាតោ រុក្ខំវ ទុព្វលំ ។

អសុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ សុសំវុតំ
ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារទ្ធវីរិយំ
តំ វេ នប្បសហតី មារោ វាតោ សេលំវ បព្វតំ។





## ១៧ - យមកវគ្គ បិដកលេខ ៥២ , ទំព័រ ២២

បុគ្គល ដែលតាមឃើញនូវអារម្មណ៍ ថាល្អ មិនសង្រួមក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូស មានព្យាយាមធូរថយ កិលេសមារ រមែងគ្របសង្កត់បុគ្គលនោះ ដូចជាខ្យល់ដែលគ្របសង្កត់ដើមឈើទុព្វល[១] ដូច្នោះឯង ។

បុគ្គល ដែលតាមឃើញនូវអារម្មណ៍ ថាមិនល្អ សង្រួមដោយប្រពៃក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន មានសទ្ធា ប្រារព្ធព្យាយាម កិលេសមាររមែងគ្របសង្កត់បុគ្គលនោះមិនបានឡើយ គឺដូចជាខ្យល់ដែលគ្របសង្កត់ភ្នំថ្មតាន់មិនបាន ដូច្នោះដែរ ។

១-ដើមឈើដែលនៅមានឫសតិចជាប់មាត់ច្រាំង ។

## ១៨~ អប្បមាទវគ្គោ ៥២/២៥-២៧

អប្បមាទោ អមតំបទំ បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា។

អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ ។

អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ
អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេធសោ។





## ១៨- អប្បមាទវគ្គ បិដកលេខ ៥២,ទំព័រ ២៥-២៧

សេចក្តីមិនប្រមាទ គឺជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់ ។ ជនទាំងឡាយដែលមិនប្រមាទហើយ ឈ្មោះថា មិនស្លាប់ ជនទាំងឡាយដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។

ចំណែកអ្នកប្រាជ្ញ រមែងរក្សាទុកនូវសេចក្តីមិនប្រមាទ ដូចគេរក្សាទុកនូវទ្រព្យដ៏ប្រសើរ ( មានកែវមណីជាដើម ) ។

បណ្ឌិត មានប្រាជ្ញាមោះមុត កាលពួកជនកំពុងប្រមាទ លោកមិនប្រមាទ កាលពួកជនកំពុងដេកលក់ លោកភ្ញាក់រលឹកច្រើន លោករមែងលះបង់ចោលនូវជនបែបនោះ ដូចសេះលឿនដែលទៅចោលសេះមានកម្លាំងខ្សោយ ដូច្នោះឯង ។

## ១៩- ចិត្តវគ្គោ ៥២/២៨-៣០

ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ
ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ ។

វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ
បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ។

ទិសោ ទិសំ យន្តំ កយិរា វេរី វា បន វេរិនំ
មិច្ឆាបណិហិតំ ចិត្តំ បាបិយោ នំ តតោ ករេ។





## ១៩- ចិត្តវគ្គ បិដកលេខ ៥២,ទំព័រ ២៨-៣០

អ្នកប្រាជ្ញ តែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបានដោយក្រ ហាមឃាត់បានដោយលំបាក ឱ្យទៅជាចិត្តត្រង់បាន ដូចអ្នកធ្វើព្រួញ រមែងពត់ព្រួញឱ្យត្រង់ ។

ចិត្តនេះដែលបុគ្គលលើកឡើងចាកកាមគុណ៥ បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់នូវវដ្តៈជាទីនៅនៃមារ រមែងញាប់ញ័រ ដូចត្រីដែលគេលើកឡើងចាកទីនៅគឺទឹក ហើយបោះទៅលើគោក ដូច្នោះឯង ។

ចោរ ក្រឡេកឃើញចោរផងគ្នា ឬក៏បុគ្គលមានពៀរ ក្រឡេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្តីវិនាសណាមួយឱ្យដល់គ្នា រីឯចិត្តដែលបុគ្គលតម្កល់ទុកខុសហើយ រមែងធ្វើបុគ្គលនោះ ឱ្យអាក្រក់ក្រៃលែងជាងសេចក្តីវិនាសនោះទៅទៀត ។

## ២០~ បុប្ផវគ្គោ ៥២/៣១-៣៣

ផេណូបមំ កាយមិមំ វិទិត្វា
មរីចិធម្មំ អភិសម្ពុធានោ
ឆេត្វាន មារស្ស បបុប្ផកានិ
អទស្សនំ មច្ចុរាជស្ស គច្ឆេ ។

យថា សង្ការធានស្មឹ ឧជ្ឈិតស្មឹ មហាបថេ
បទុមំ តត្ថ ជាយេថ សុចិគន្ធំ មនោរមំ
ឯវំ សង្ការភូតេសុ អន្ធភូតេ បុថុជ្ជនេ
អតិរោចតិ បញ្ញាយ សម្មាសម្ពុទ្ធសាវកោ ។





## ២០ - បុប្ផវគ្គ បិដកលេខ ៥២,ទំព័រ ៣១-៣៣

បុគ្គល កាលដឹងច្បាស់នូវកាយនេះថា ដូចជាពពុះទឹក ដឹងច្បាស់ប្រាកដថា កាយនេះមានសភាពដូចជាថ្ងៃបណ្តើរកូន គប្បីកាត់ចោលនូវកម្រងផ្ការបស់មារគឺវដ្តៈទាំង ៣ ទៅកាន់ទីដែលមច្ចុរាជមើលមិនឃើញ ។

ផ្កាឈូក មានក្លិនក្រអូបឈ្ងុយឈ្ងប់ ដុះឡើងក្នុងគំនរសំរាម ដែលគេចាក់ចោលក្បែរផ្លូវធំ ជាផ្កាដែលជាទីពេញចិត្ត ( ដល់អ្នកដើរ ) យ៉ាងណាមិញ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ទោះបីកើតនៅក្នុងសមាគមនៃពួកជនដែលដូចជាគំនរសំរាមក៏ដោយ ក៏នៅតែរុងរឿងដោយបញ្ញា លើសបុថុជ្ជនទាំងឡាយ ដែលងងឹតសូន្យឈឹង ក៏យ៉ាងនោះដែរ ។

## ២១‿ ពាលវគ្គោ ៥២/៣៥-៣៦

យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ
ន សោ ធម្មំ វិជានាតិ ទព្វី សូបរសំ យថា ។

មុហុត្តមបិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ
ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា ។

ន ហិ បាបំ កតំ កម្មំ សជ្ជុខីរំវ មុច្ចតិ
ឌហន្តំ ពាលមន្វេតិ ភស្មាច្ឆន្នោវ បាវកោ។





## ២១ - ពាលវគ្គ បិដកលេខ ៥២,ទំព័រ ៣៥-៣៦

ជនពាល បើចូលទៅអង្គុយជិតបណ្ឌិត សូម្បីអស់មួយជីវិត ក៏ឥតបានដឹងនូវធម្មរសដែរ[១] ដូចវែកដែលមិនដឹងនូវរសសម្ល ។

វិញ្ញូជន បើចូលទៅអង្គុយជិតបណ្ឌិត សូម្បីតែមួយរំពេច ក៏រមែងបានដឹងនូវធម្មរសដោយឆាប់រហ័ស ដូចអណ្ដាតដឹងនូវរសសម្ល ។

កម្មលាមក ដែលជនពាលធ្វើហើយ មិនទាន់ហុចផលឱ្យ ប្រៀបដូចជាទឹកដោះស្រស់ដែលមិនទាន់ប្រែក្លាយទៅជូរច្នោះ បាបកម្មនោះ រមែងតាមដុតបុគ្គលពាល ដូចរងើកភ្លើងដែលបិទបាំងទុកដោយផេះ យ៉ាងនោះឯង ។

---

១.ល្ងង់តែលើកតម្កើងខ្លួន ធ្វើជាអ្នកចេះ មិនសិក្សាបដិបត្តិក្នុងព្រះធម៌ ។

## ២២- បណ្ឌិតវគ្គោ ៥២/៣៧-៣៨

និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ
និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ
តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ។

យថាបិ រហទោ គម្ភីរោ វិប្បសន្នោ អនាវិលោ
ឯវំ ធម្មានិ សុត្វាន វិប្បសីទន្តិ បណ្ឌិតា ។





## ២២ - បណ្ឌិតវគ្គ បិដកលេខ ៥២,ទំព័រ ៣៧-៣៨

បុគ្គល គប្បីសម្លឹងមើលអ្នកណាម្នាក់ ដែលជាអ្នកមានប្រាជ្ញា និយាយចង្អុលបង្ហាញទោសឱ្យឃើញជាក់ច្បាស់ ដូចជាអ្នកចង្អុលបង្ហាញនូវកំណប់ទ្រព្យឱ្យដូច្នោះ គប្បីសេពគប់នឹងអ្នកប្រាជ្ញ ដែលលោកជាបណ្ឌិតនោះ ( ព្រោះថា ) កាលបុគ្គលគប់រកអ្នកប្រាជ្ញបែបនោះហើយ រមែងមានតែការគាប់ប្រសើរ ឥតមានទោសពៃរ៍អ្វីអាក្រក់ឡើយ ។

អន្លង់ទឹកជ្រៅ ថ្លាស្អាត មិនមានកករល្អក់ យ៉ាងណាមិញ បណ្ឌិតទាំងឡាយ កាលបើបានស្ដាប់នូវព្រះធម៌ទេសនាហើយ រមែងជ្រះថ្លាស៊ប់ស្ងួន ( មានចិត្តមិនកករល្អក់ ) យ៉ាងនោះឯង ។

## ២៣~ អរហន្តវគ្គោ ៥២/៤១

ឧយ្យុញ្ជន្តិ សតីមន្តោ ន និកេតេ រមន្តិ តេ
ហំសាវ បល្លលំ ហិត្វា ឱកមោកំ ជហន្តិ តេ ។

យស្សាសវា បរិក្ខីណា អាហារេ ច អនិស្សិតោ
សុញ្ញតោ អនិមិត្តោ ច វិមោក្ខោ យស្ស គោចរោ
អាកាសេវ សកុន្តានំ បទន្តស្ស ទុរន្នយំ[១] ។

១~ទុរន្វយំ ។ អដ្ឋកថា ។





## ២៣ – អរហន្តវគ្គ បិដកលេខ ៥២,ទំព័រ ៤១

ព្រះខីណាស្រពទាំងឡាយ ជាបុគ្គលមានស្មារតីព្យាយាម លោកមិនត្រេកអរក្នុងទីនៅអាស្រ័យ លោកលះបង់ចោលស្រឡះនូវអាល័យ គឺការហួងហែងទាំងពួងបីដូចជាសត្វហង្ស លះបង់នូវភក់ជ្រាំ ហើយហើរទៅដូច្នោះឯង ។

អាសវៈនៃបុគ្គលណា អស់ហើយ បុគ្គលណាមិនអាស្រ័យដោយតណ្ហា និងទិដ្ឋិក្នុងអាហារ និងបុគ្គលណាមានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ ( និងអប្បណិហិត-វិមោក្ខ ) ជាគោចរ ដំណើររបស់បុគ្គលនោះ គេកម្រដឹងបានណាស់ ដូចដំណើរនៃពួកសត្វស្លាបឰដ៏អាកាស[១] ដូច្នោះឯង ។

១-មិនមានស្នាមជើងក្នុងអាកាស ។

## ២៤~ បាបវគ្គោ ៥២/៤៧-៤៨

មាវមញ្ញេថ បាបស្ស ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
អាបូរតិ ពាលោ បាបស្ស ថោកំ ថោកំបិ អាចិនំ។

វាណិជោវ ភយំ មគ្គំ អប្បសត្ថោ មហទ្ធនោ
វិសំ ជីវិតុកាមោវ បាបានិ បរិវជ្ជយេ ។

បាណិម្ហិ ចេ វណោ នាស្ស ហរេយ្យ បាណិនា វិសំ
នាព្វណំ វិសមន្វេតិ នត្ថិ បាបំ អកុព្វតោ។





## ២៤ – បាបវគ្គ បិដកលេខ ៥២,ទំព័រ ៤៧-៤៨

បុគ្គល មិនគួរមើលងាយបាបថា មានប្រមាណតិច នឹងមិនឱ្យផលដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះមក។ បុគ្គលពាល កាលសន្សំបាប សូម្បីបន្តិចម្តងៗ គង់ពេញបានដោយបាប ។

បុគ្គល គួរជៀសវាងបាបទាំងឡាយ ឱ្យដូចនាយពាណិជដែលមានទ្រព្យច្រើន តែមានគ្នាតិច គេចចេញពីផ្លូវដែលមានភ័យ ឬដូចបុគ្គលដែលប្រាថ្នាការរស់នៅ បានជៀសវាងនូវថ្នាំពិស ដូច្នោះដែរ ។

បើដំបៅមិនមានក្នុងបាតដៃទេ បុគ្គលគប្បីនាំយកនូវថ្នាំពិសដោយបាតដៃបាន ថ្នាំពិសមិនអាចជ្រាបចូលទៅតាមបាតដៃដែលគ្មានដំបៅនោះបានឡើយ យ៉ាងណាមិញ បាប រមែងមិនមានដល់បុគ្គលអ្នកមិនធ្វើ យ៉ាងនោះឯង ។

## ២៥~ ទណ្ឌវគ្គោ ៥២/៥០-៥២

យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ
ឯវំ ជរា ច មច្ចុ ច អាយុំ បាជេន្តិ បាណិនំ។

ហិរីនិសេធោ បុរិសោ កោចិ លោកស្មិ វិជ្ជតិ
យោ និទ្ទំ អបពោធេតិ អស្សោ ភទ្រោ កសាមិវ។

អស្សោ យថា ភទ្រោ កសានិវិដ្ឋោ
អាតាបិនោ សំវេគិនោ ភវាថ ។





## **២៥- ទណ្ឌវគ្គ** បិដកលេខ ៥២,ទំព័រ ៥០-៥២

គង្វាលគោ កៀងគោទាំងឡាយ ទៅកាន់ទីគោចរ ដោយអាជ្ញាគឺដំបង ឬរំពាត់ យ៉ាងណាមិញ ជរាគឺសេចក្តីទ្រុឌទ្រោមគ្រាំគ្រា និងមច្ចុរាជគឺសេចក្តីស្លាប់ ក៏កៀងទៅនូវអាយុរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។

បុរស អាចហាមនូវអកុសលវិតក្កបានដោយហិរិ មានតិចនាក់ណាស់ក្នុងលោក បុគ្គលណា កម្ចាត់បង់ការដេកលក់ ប្រញាប់ក្រោកឡើង ដូចជាសេះល្អខ្លាចរំពាត់[១] បុគ្គលនោះ រកបានដោយក្រ ក្នុងលោក ។

សេះល្អ បាននាយសារថីទូន្មានដោយរំពាត់ហើយ ក៏មានការប្រឹងប្រែង យ៉ាងណា អ្នកទាំងឡាយ ចូរជាបុគ្គលមានព្យាយាម មាននូវសេចក្តីសង្វេគតក់ស្លុតចំពោះទុក្ខ ក៏យ៉ាងនោះដែរ ។

---

១-មិនឱ្យខ្លួនត្រូវរំពាត់ ។

## ២៦. ជរាវគ្គោ ៥២/៥៤

អប្បស្សុតាយំ បុរិសោ   ពលិពទ្ទោវ ជីរតិ
មំសានិ តស្ស វឌ្ឍន្តិ   បញ្ញា តស្ស ន វឌ្ឍតិ។

អនេកជាតិសំសារំ   សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ   ទុក្ខា ជាតិ បុនប្បុនំ ។
គហការក ទិដ្ឋោសិ   បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា   គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ   តណ្ហានំ ខយមជ្ឈគា ។





## ២៦ - ជរាវគ្គ បិដកលេខ ៥២,ទំព័រ ៥៤

បុរស អ្នកមិនមានការចេះដឹងនេះ តែងចាស់ឥតអំពើ ដូចគោបម្រើ ( ចាស់ហើយគេលែងប្រើ ) សាច់របស់វាតែងចម្រើនឡើង តែប្រាជ្ញារបស់វាមិនចម្រើនឡើយ ។

តថាគត កាលដែលកំពុងតែស្វះស្វែងរកជាងធ្វើផ្ទះ ពោលគឺតណ្ហា មិនទាន់បានជួបប្រទះនៅឡើយ បានវិលវល់ អន្ទោលទៅកាន់សង្សារវដ្ត មានជាតិជាអនេកម្ល៉ោះហើយ ជាតិបាននាំមកនូវទុក្ខរឿយៗ ។

នែជាងផ្ទះ! យើងរកអ្នកឃើញហើយ អ្នកនឹងធ្វើផ្ទះ គឺអត្តភាពឱ្យយើងទៀតពុំបានឡើយ ឆ្អឹងជំនីរ គឺកិលេសទាំងអស់របស់អ្នក យើងកាច់បំបាក់អស់ហើយ ដំបូលផ្ទះ គឺអវិជ្ជា យើងកម្ទាត់ចោលហើយ ចិត្តរបស់យើងទៅរកវិសង្ខារ បានដល់នូវការអស់តណ្ហាទាំងពួងហើយ ។

## ២៧~ អត្តវគ្គោ ៥២/៥៥-៥៦

អត្តនា ហ កតំ បាបំ  អត្តជំ អត្តសម្ភវំ
អភិមត្ថតិ ទុម្មេធំ  វជិរំវម្ហយំ មណឹ ។

យស្ស អច្ចន្តទុស្សីល្យំ  មាលុវា សាលមិវោត្ថតំ
ករោតិ សោ តថត្តានំ  យថា នំ ឥច្ឆតី ទិសោ។

យោ សាសនំ អរហតំ  អរិយានំ ធម្មជីវិនំ
បដិក្កោសតិ ទុម្មេធោ  ទិដ្ឋឹ និស្សាយ បាបិកំ
ផលានិ កណ្ដកស្សេវ  អត្តឃញ្ញាយ ផល្លតិ ។





## ២៧ - អត្តវគ្គ បិដកលេខ ៥២,ទំព័រ ៥៥-៥៦

បាប ដែលខ្លួនធ្វើហើយ កើតក្នុងខ្លួន មានខ្លួនជាដែនកើត រមែងញាំញីគ្របសង្កត់នូវបុគ្គលដែលអាប់ប្រាជ្ញា ដូចពេជ្រកាត់នូវកែវមណីដែលកើតពីថ្ម ដូច្នោះឯង ។

ភាពនៃ ( តណ្ហាដែលធ្វើបុគ្គលឱ្យទៅជា ) អ្នកទ្រុស្តសីលហួសកម្រិត គ្របសង្កត់អត្តភាពនៃបុគ្គលណា ដូចវល្លិដែលរួបរឹតដើមឈើ បុគ្គលនោះ ឈ្មោះថាធ្វើខ្លួនឯងឱ្យដូចជាចោរ ដែលប្រាថ្នានូវការវិនាសដល់ខ្លួន ដូច្នោះឯង ។

បុគ្គលណា អាប់ប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមកហាមឃាត់សាសនារបស់ព្រះអរិយៈទាំងឡាយ ដែលជាព្រះអរហន្តមានប្រក្រតីនៅប្រកបដោយធម៌ ការហាម-ឃាត់ របស់បុគ្គលនោះ រមែងចេញផលមកដើម្បីសម្លាប់ខ្លួនឯង ដូចជាផ្លែឫស្សី ( សម្លាប់ដើម ) ដូច្នោះដែរ ។

## ២៨- លោកវគ្គោ ៥២/៥៨

យថា បុព្វុឡកំ បស្សេ យថា បស្សេ មរីចិកំ
ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។

ឯថ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ
យត្ថ ពាលា វិសីទន្តិ នត្ថិ សង្គោ វិជានតំ ។

អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ
សកុណោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ។





## ២៨- លោកវគ្គ បិដកលេខ ៥២,ទំព័រ ៥៨

បុគ្គល ឃើញពពុះទឹកយ៉ាងណា ឃើញថ្ងៃបណ្តើរកូនយ៉ាងណា មច្ចុរាជរមែងមើលមិនឃើញឡើយនូវបុគ្គលដែលពិចារណាឃើញនូវខន្ធលោក (ថាដូចជាពពុះទឹកឬថ្ងៃបណ្តើរកូន) យ៉ាងនោះឯង ។

អ្នកទាំងឡាយ ចូរមកមើលនូវលោកនេះ ដ៏វិចិត្រដូចជារាជរថ។ ពួកជនពាលជាប់ជំពាក់លិចលង់ក្នុងលោកណា ការជាប់ជំពាក់ក្នុងលោកនោះ រមែងមិនមានដល់ជនជាបណ្ឌិតទាំងឡាយ ដែលជាអ្នកដឹងច្បាស់ឡើយ ។

លោកិយមហាជននេះ ងងឹតដូចមនុស្សខ្វាក់ភ្នែក តិចនាក់ណាស់ ដែលបានដឹងច្បាស់នូវលោកនេះតាមពិត ទាំងដែលទៅកាន់ស្ថានសួគ៌ក៏តិចដែរ ដូចជាបក្សី (កាលដែលជាប់សំណាញ់របស់ព្រានហើយ) តិចណាស់ ដែលបានរួចពីសំណាញ់ ដូច្នោះឯង ។

## ២៩_ សុខវគ្គោ ៥២/៦៤-៦៥

ពាលសង្គតចរី ហិ ទីឃមទ្ធាន សោចតិ
ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វទា
ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ ។

ធីរញ្ច បញ្ញញ្ច ពហុស្សុតញ្ច
ធោរយ្ហសីលំ វតវន្តមរិយំ
តំ តាទិសំ សប្បុរិសំ សុមេធំ
ភជេថ នក្ខត្តបថំវ ចន្ទិមា ។





## ២៩- សុខវគ្គ បិដកលេខ ៥២,ទំព័រ ៦៤-៦៥

បុគ្គល ដែលបានប្រព្រឹត្តរួមសមាគមជាមួយនឹងជនពាល រមែងសោកស្តាយអស់កាលយូរអង្វែង ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខសព្វកាល ដូចការនៅរួមជាមួយនឹងសត្រូវ យ៉ាងនោះឯង ចំណែកឯការនៅរួមនឹងធីរជនវិញ រមែងជាសុខ ដូចជាសមាគមនៃពួកញាតិ ។

បុគ្គល គប្បីសេពគប់នឹងសប្បុរស ដែលលោកជាអ្នកមាំមួនផង មានបញ្ញាផង មានការចេះដឹងច្រើនផង មានកិរិយានាំទៅនូវធុរៈជាប្រក្រតីផង[១] មានសីលវត្តនិងធុតង្គវត្តផង ជាអ្នកឆ្ងាយចាកកិលេសផង និងមានបញ្ញាឈ្លាសវាងវៃល្អផង ប្រាកដដូច្នោះឯង ឱ្យដូចជាព្រះចន្ទគប់នូវផ្លូវនក្ខត្តឫក្ស ។

១_មានព្យាយាមមិនដាក់ចុះ រហូតដល់ព្រះអរហត្ត ។ អដ្ឋកថា ។

## ៣០~ បិយវគ្គោ ៥២/៦៧

ចិរប្បវាសឹ បុរិសំ ទូរតោ សោត្ថិមាគតំ
ញាតី មិត្តា សុហជ្ជា ច អភិនន្ទន្តិ អាគតំ
តថេវ កតបុញ្ញម្បិ អស្មា លោកា បរំ គតំ
បុញ្ញានិ បដិគណ្ហន្តិ បិយំ ញាតីវ អាគតំ។

## កោធវគ្គោ ៥២/៦៨

យោ វេ ឧប្បតិតំ កោធំ រថំ ភន្តំវ ធារយេ
តមហំ សារថឹ ព្រូមិ រស្មិគ្គាហោ ឥតរោ ជនោ។





## ៣០ - **បិយវគ្គ** បិដកលេខ ៥២,ទំព័រ ៦៧

ពួកញាតិក្តី មិត្តក្តី សម្លាញ់ក្តី រមែងត្រេកអរនឹងការមកដល់ នៃបុរសដែលឃ្លាតគ្នាអស់កាលដ៏យូរហើយមកអំពីចម្ងាយដោយសួស្តី យ៉ាងណាមិញ បុណ្យទាំង-ឡាយ តែងទទួលបុគ្គលដែលបានធ្វើបុណ្យទុកហើយ លះលោកនេះទៅកាន់លោកខាងមុខ[១] ដូចញាតិទាំងឡាយទទួលបុរសជាទីស្រឡាញ់ទើបមកដល់ យ៉ាងនោះឯង ។

## **កោធវគ្គ** បិដកលេខ ៥២,ទំព័រ ៦៨

បុគ្គលណា ឃាត់សេចក្តីក្រោធ ដែលកើតឡើងហើយ ដូចជាគេទប់រថដែលកំពុងលឿនបាន តថាគតហៅបុគ្គលនោះ ថាជាសារថី ជនក្រៅពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែបរប៉ុណ្ណោះ ។

---

១-ទទួលដោយអាយុ វណ្ណៈ សុខៈ យស និងភាពជាអធិបតី ព្រមទាំងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ដែលទាំងអស់សុទ្ធតែជាទិព្វ ។ អដ្ឋកថា ។

## ៣១~ មលវគ្គោ ៥២/៧០-៧១

បណ្ឌុបលាសោវទានិសិ
យមបុរិសាបិ ច តេ ឧបដ្ឋិតា
ឧយ្យោគមុខេ ច តិដ្ឋសិ
បាថេយ្យម្បិ ច តេ ន វិជ្ជតិ។
សោ ករោហិ ទីបមត្តនោ
ខិប្បំ វាយម បណ្ឌិតោ ភវ
និទ្ធន្តមលោ អនង្គណោ
ទិព្វំ អរិយភូមិមេហិសិ ។

អនុបុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ
កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។





## ៣១- មលវគ្គ បិដកលេខ ៥២,ទំព័រ ៧០-៧១

ឥឡូវនេះ ខ្លួនអ្នកដូចស្លឹកឈើទុំ មានពណ៌លឿងហើយ ទាំងពួកបុរសបម្រើយមរាជគឺសេចក្តីស្លាប់ ប្រាកដដល់អ្នកហើយ ខ្លួនអ្នកតាំងនៅក្នុងមាត់នៃសេចក្តីវិនាស សូម្បីស្បៀងគឺកុសលរបស់អ្នក ក៏មិនទាន់មានដែរ ។

អ្នក ចូរធ្វើនូវកុសលឱ្យជាទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមរួតរះ និងចូរជាអ្នកឆ្លាតឈ្លាស (កុំជាមនុស្សល្ងង់ខ្លៅឡើយ)បើអ្នក (ធ្វើយ៉ាងនេះហើយ) អ្នកនឹងកម្ចាត់បង់នូវមន្ទិលបាន មិនមានទីទួលគឺកិលេស អ្នកនឹងដល់នូវអរិយភូមិដ៏ជាទិព្វ ។

អ្នកមានប្រាជ្ញា គួរកម្ចាត់បង់នូវមន្ទិលរបស់ខ្លួនបន្តិចម្តងៗ រាល់ៗខណៈដោយលំដាប់ ដូចជាងមាសជម្រះនូវស្នឹមនៃមាសដូច្នោះឯង ។

## ៣២~ មគ្គវគ្គោ ៥២/៨០-៨១

យាវញ្ហិ វនថោ ន ឆិជ្ជតិ
អណុមត្តោបិ នរស្ស នារិសុ
បដិពទ្ធមនោ វ តាវ សោ
វច្ឆោ ខីរបកោវ មាតរិ ។

ឧច្ឆិន្ទ សិនេហមត្តនោ
កុមុទំ សារទិកំវ បាណិនា
សន្តិមគ្គមេវ ព្រូហយ
និព្វានំ សុគតេន ទេសិតំ ។
តំ បុត្តបសុសម្មត្តំ ព្យាសត្តមនសំ នរំ
សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។





## ៣២ - មគ្គវគ្គ បិដកលេខ ៥២,ទំព័រ ៨០-៨១

កិលេសរបស់មនុស្ស ដូចជាដើមឈើដុះក្នុងព្រៃ សូម្បីមានប្រមាណតិចក៏ដោយ បើកាត់មិនដាច់ក្នុងពួកនារី ដរាបណា មនុស្សនោះឯង តែងមានចិត្តជាប់ជំពាក់ក្នុងពួកនារី ដរាបនោះ ដូចកូនគោនៅកំពុងបៅដោះ មានចិត្តប្រតិព័ទ្ធនឹងមេ ដូច្នោះឯង ។

អ្នក ចូរដកសេចក្តីស្នេហារបស់ខ្លួនចេញ ដូចបុគ្គលដកផ្កាកុមុទ (ជលជាត) ដែលកើតក្នុងសរទកាលដោយដៃ អ្នកចូរចម្រើននូវមគ្គដែលជាផ្លូវសន្តិភាពតែម្យ៉ាង ព្រោះព្រះនិព្វាន ព្រះសុគតទ្រង់ត្រាស់សម្តែងទុកហើយ ។

មច្ចុគឺសេចក្តីស្លាប់ តែងនាំយកទៅនូវជនអ្នកដែលស្រវឹងជ្រប់ក្នុងកូននិងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗនោះ ដូចជំនន់ទឹកធំ នាំយកទៅនូវអ្នកស្រុកដែលកំពុងដេកលក់ ដូច្នោះឯង ។

## ៣៣_ បកិណ្ណកវគ្គោ ៥២/៨៤

ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ
អសន្តេត្ថ ន ទិស្សន្តិ រត្តឹ ខិត្តា យថា សរា ។

## និរយវគ្គោ ៥២/៨៧

នគរំ យថា បច្ចន្តំ គុត្តំ សន្តរពាហិរំ
ឯវំ គោបេថ អត្តានំ ខណោ មា វោ ឧបច្ចគា[១]
ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា ។

១_ខណោ វោ មា ឧបច្ចគា ។ អដ្ឋកថា ។





## ៣៣ – បកិណ្ណកវគ្គ បិដកលេខ ៥២,ទំព័រ ៨៤

ពួកសប្បុរស រមែងប្រាកដក្នុងទីឆ្ងាយ[១] ដូចភ្នំហិមពាន្តដូច្នោះឯង ឯពួកអសប្បុរស ( ទោះជាឋិតនៅក្នុងទីជិតក៏ដោយ ) ក៏រមែងមិនប្រាកដ ដូចព្រួញដែលបុគ្គលបាញ់ក្នុងពេលយប់ ដូច្នោះដែរ ។

## និរយវគ្គ បិដកលេខ ៥២,ទំព័រ ៨៧

បច្ចន្តនគរ ដែលគេគ្រប់គ្រងហើយ ទាំងខាងក្នុងទាំងខាងក្រៅ យ៉ាងណាមិញ អ្នកទាំងឡាយគួររក្សាខ្លួនយ៉ាងនេះឯង កុំឱ្យខណៈ[២] កន្លងនូវអ្នកទាំងឡាយឡើយ ព្រោះថា ជនទាំងឡាយ ដែលឱ្យខណៈកន្លងហើយ រមែងសោកស្តាយក្នុងនរក មីរដេរដាស ។

១_សូម្បីនៅឆ្ងាយយ៉ាងណា ក៏ប្រាកដក្នុងព្រះញាណរបស់ព្រះសម្មាសម្ពុទ្ធដែរ ។ ២_ខណៈនៃការរក្សាខ្លួនដោយសម្មាទិដ្ឋិក្នុងព្រះពុទ្ធសាសនា ។

## ៣៤~ នាគវគ្គោ ៥២/៨៨-៩០

អហំ នាគោវ សង្គាមេ ចាបាតោ បតិតំ សរំ
អតិវាក្យន្តិតិក្ខិស្សំ ទុស្សីលោ ហិ ពហុជ្ជនោ។

មិន្តំ យទា ហោតិ មហគ្ឃសោ ច
និទ្ទាយិតា សម្បរិវត្តសាយី
មហាវរាហោវ និវាបបុដ្ឋោ
បុនប្បុនំ គព្ភមុបេតិ មន្ទោ ។

អប្បមាទរតា ហោថ សចិត្តមនុរក្ខថ
ទុគ្គា ឧទ្ធរថត្តានំ បង្កេ សន្នោវ កុញ្ជរោ។





## ៣៤- នាគវគ្គ បិដកលេខ ៥២,ទំព័រ ៨៨-៩០

តថាគត នឹងអត់ធន់ចំពោះពាក្យសម្តី ដែលអ្នកដទៃនិយាយហួសប្រមាណ ដូចជាដំរីដែលមានសេចក្តីអត់ធន់ចំពោះព្រួញ ដែលគេបាញ់ចេញអំពីធ្នូក្នុងសង្គ្រាម ដូច្នោះឯង ព្រោះថា មនុស្សទ្រុស្តសីលមានច្រើននាក់ ។

កាលណា បុគ្គលបរិភោគភោជនមានប្រមាណច្រើនផង ងោកងុយផង ចូលចិត្តដេកច្រើនផង និងដេកបម្រះនឿលផង ដូចជាជ្រូកស្រុកដែលគេបំប៉នដោយអាហារ កាលនោះ បុគ្គលនោះ ជាមនុស្សល្ងង់ខ្លៅ រមែងចូលទៅកាន់គភ៌រឿយៗ ។

អ្នកទាំងឡាយ ចូរត្រេកអរក្នុងសេចក្តីមិនប្រមាទ ចូររក្សាចិត្តរបស់ខ្លួនឱ្យបានរឿយៗ ចូររើខ្លួនឡើងចាកភក់គឺកិលេស ដែលឆ្លងបានដោយក្រ ដូចជាដំរីដែលជាប់ភក់ហើយរើខ្លួនរួចបាន ដូច្នោះឯង ។

## ៣៥~ តណ្ហាវគ្គោ ៥២/៩១-៩២

មនុជស្ស បមត្តចារិនោ
តណ្ហា វឌ្ឍតិ មាលុវា វិយ
សោ បលវតី ហុរាហុរំ
ផលមិច្ឆំវ វនស្មឹ វានរោ ។

យំ ឯសា សហតី ជម្មី តណ្ហា លោកេ វិសត្តិកា
សោកា តស្ស បវឌ្ឍន្តិ អភិវឌ្ឍំវ ពីរណំ ។
យោ ចេ តំ សហតី ជម្មឹ តណ្ហំ លោកេ ទុរច្ចយំ
សោកា តម្ហា បបតន្តិ ឧទពិន្ទុវ បោក្ខរា ។





## ៣៥- តណ្ហាវគ្គ បិដកលេខ ៥២,ទំព័រ ៩១-៩២

តណ្ហា តែងចម្រើនដល់មនុស្សដែលមានប្រក្រតីប្រព្រឹត្តដោយសេចក្តីប្រមាទ ដូចវល្លិរួបរឹតនូវដើមឈើហើយចម្រើនឡើង បុគ្គលនោះ តែងស្ទុះទៅកាន់ភពតូចនិងភពធំ ដូចស្វា កាលប្រាថ្នានូវផ្លែឈើ រមែងលោតទៅក្នុងព្រៃ ដូច្នោះឯង ។

តណ្ហានោះ ជាទោសជាតិដ៏លាមក ផ្សាយទៅក្នុងលោក បានគ្របសង្កត់ជនណា ការសោកសៅក៏ចម្រើនឡើងដល់ជននោះ ដូចស្មៅវរណ្តាស ដែលត្រូវភ្លៀងធ្លាក់ចុះជព្រំ ហើយពន្លកក៏លូតឡើង ដូច្នោះដែរ ។

ចំណែកជនណា គ្របសង្កត់នូវតណ្ហាដ៏លាមកក្នុងលោកដែលគេឆ្លងបានដោយក្រនោះ ការសោកសៅរមែងធ្លាក់ចេញអំពីជននោះឯង ដូចតំណក់ទឹកធ្លាក់ពីស្លឹកឈូក ក៏ដូច្នោះដែរ ។

## ៣៦_ តណ្ហាវគ្គោ ៥២/៩២-៩៤-៩៥

យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ
ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ
ឯវម្បិ តណ្ហានុសយេ អនូហតេ
និព្វត្តតី ទុក្ខមិទំ បុនប្បុនំ ។

តសិណាយ បុរក្ខតា បជា
បរិសប្បន្តិ សសោវ ពាធិតោ ។

យេ រាគរត្តានុបតន្តិ សោតំ
សយំ កតំ មក្កដកោវ ជាលំ
ឯតម្បិ ឆេត្វាន វជន្តិ ធីរា
អនបេក្ខិនោ សព្វទុក្ខំ បហាយ ។





## ៣៦ -តណ្ហាវគ្គ បិដកលេខ ៥២,ទំព័រ ៩២-៩៤-៩៥

កាលបើឫសឈើមិនមានអន្តរាយទេ នៅមាំមួនល្អដូច្នេះ ទោះជាកាប់ដើមឈើនោះចោលក៏ដោយ វារមែងដុះឡើងទៀតបាន មានឧបមាដូចម្តេចមិញ កាលបើតណ្ហានុស័យ បុគ្គលមិនទាន់កម្ចាត់បានហើយ សេចក្តីទុក្ខនេះឯងក៏តែងកើតរឿយៗ មានឧបមេយ្យ ដូច្នោះដែរ ។

ពួកសត្វ ដែលត្រូវតណ្ហាជាគ្រឿងតក់ស្លុតក្រុងទុកហើយ រមែងរន្ធត់តក់ស្លុត ដូចជាទន្សាយដែលត្រូវព្រានទាក់ចាប់បាន ដូច្នោះដែរ ។

ពួកជនណាត្រេកអរដោយរាគៈ ពួកជននោះរមែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចជាសត្វពីងពាងស្ទុះទៅតាមសំណាញ់ដែលខ្លួនបានធ្វើ (ដើម្បីចាប់ចំណី) ដូច្នេះឯង ។ អ្នកប្រាជ្ញទាំងឡាយ តែងកាត់ខ្សែតណ្ហានោះ ជាអ្នកមិនមានអាល័យហើយ លះទុក្ខទាំងពួងបាន ។

## ៣៧_ពោធិ. មេឃិយវគ្គស្ស ៥២/១១៧-២០៨

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
វិធូបយំ តិដ្ឋតិ មារសេនំ
សុរិយោវ ឱភាសយមន្តលិក្ខន្តិ ។

យស្ស សេលុបមំ ចិត្តំ ឋិតំ នានុបកម្បតិ
វិរត្តំ រជនីយេសុ កោបនេយ្យេ ន កុប្បតិ
យស្សេវំ ភាវិតំ ចិត្តំ កុតោ តំ ទុក្ខមេស្សតីតិ ។





## ៣៧_ពោធិ. មេឃិយវគ្គ បិដក ៥២,ទំ.១១៧_២០៨

ក្នុងកាលណា ធម៌ទាំងឡាយប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាមញាំងកិលេសឱ្យក្តៅ ដុតនូវកិលេស ក្នុងកាលនោះ ព្រាហ្មណ៍នោះឯង រមែងកម្ចាត់បង់នូវមារព្រមទាំងសេនាមារ ហើយឋិតនៅ បីដូចជាព្រះអាទិត្យរះឡើង ធ្វើអាកាសឱ្យរុងរឿងដោយរស្មីរបស់ខ្លួន កម្ចាត់បង់នូវងងឹត ហើយឋិតនៅ ដូច្នោះឯង ។

ចិត្តនៃបុគ្គលណា មានឧបមាដូចភ្នំថ្ម នៅនឹងមិនញាប់ញ័រ ប្រាសចាកតម្រេកក្នុងអារម្មណ៍ដែលគួរឱ្យរីករាយទាំងឡាយ មិនក្រោធក្នុងអារម្មណ៍ដែលជាទីតាំងនៃសេចក្តីក្រោធ ។ ចិត្តដែលបុគ្គលណា បានអប់រំឱ្យចម្រើនហើយយ៉ាងនេះ សេចក្តីទុក្ខនឹងធ្លាក់ចុះមកដល់បុគ្គលនោះដូចម្តេចបាន ។

## ៣៨~ជច្ចន្ធ. ចូឡវគ្គស្ស ៥២/៣០៤-៣១១

ឧបាតិធាវន្តិ ន សារមេន្តិ
នវំ នវំ ពន្ធនំ ព្រូហយន្តិ
បតន្តិ បជ្ជោតមិវាធិបាតា
ទិដ្ឋេ សុតេ ឥតិហេកេ និវិដ្ឋាតិ ។

កាមន្ធា ជាលសញ្ឆន្នា តណ្ហាឆទនឆាទិតា
បមត្តពន្ធុនា ពន្ធា មច្ឆាវ កុម្មិនាមុខេ
ជរាមរណំ គច្ឆន្តិ វច្ឆោ ខីរបកោវ មាតរន្តិ ។





## ៣៨~ ជច្ចន្ធ. ចូឡវគ្គ បិដក ៥២,ទំព័រ ៣០៤-៣១១

សមណព្រាហ្មណ៍ទាំងឡាយ មិនទាន់បានត្រាស់-ដឹងនូវសារធម៌ មានសីលជាដើម ក៏រមែងមានការប្រកាន់មាំ តែងញុំាងនូវចំណងថ្មីៗគឺតណ្ហានិងទិដ្ឋិ ឱ្យចម្រើន ។ សមណព្រាហ្មណ៍ពួកខ្លះ ប្រកាន់មាំក្នុងរូបដែលបានឃើញ និងសំឡេងដែលបានឮ ហើយរមែងធ្លាក់ចុះ (ក្នុងភ្នក់ភ្លើង គឺភព ៣ ) ដូចជាសត្វមមាច ដែលធ្លាក់ចូលក្នុងអណ្តាតភ្លើង ដូច្នោះឯង ។

ជនទាំងឡាយ ងងឹតព្រោះកាម ដែលបណ្តាញគឺតណ្ហារួបរឹត ត្រូវដំបូលគឺតណ្ហាបាំងបិទ ជាប់នៅដោយកិលេសមារ ដូចជាពួកត្រីនៅក្នុងលប រមែងដល់នូវជរា និងមរណៈ ឬដូចជាកូនគោនៅបៅដោះ តែងចូលទៅរកមេរបស់វា ដូច្នោះដែរ ។

## ៣៩_តិកនិបាតស្ស ៥៣/៩៣-១២០-៦៧

បរិត្តំ ទារុមារុយ្ហ    យថា សីទេ មហណ្ណវេ
ឯវំ កុសីតមាគម្ម    សាធុជីវីបិ សីទតិ ។

គិហិភោគា ច បរិហីនោ    សាមញ្ញត្ថញ្ច ទុព្ភគោ
បរិធំសមានោ បកិរេតិ    ឆវាលាតំ វ នស្សតិ។

សីលសមាធិបញ្ញា ច    យស្ស ឯតេ សុភាវិតា
អតិក្កម្ម មារធេយ្យំ    អាទិច្ចោវ វិរោចតីតិ។





## ៣៩_ តិកនិបាត បិដក ៥៣,ទំព័រ ៩៣-១២០-៦៧

បុគ្គល ដែលប្រាថ្នានឹងឆ្លងមហាសមុទ្រ ប៉ុន្តែឡើងកាន់ក្បូនឈើដ៏តូច ក៏រមែងលិចចុះទៅក្នុងមហាសមុទ្រ យ៉ាងណាមិញ បុគ្គលដែលចិញ្ចឹមជីវិតដោយប្រពៃ ប៉ុន្តែអាស្រ័យនឹងបុគ្គលខ្ជិលច្រអូស ក៏រមែងលិចចុះក្នុងមហាសមុទ្រគឺវដ្តសង្សារ យ៉ាងនោះឯង ។

ភិក្ខុទ្រុស្តសីល រមែងសាបសូន្យចាកភោគៈរបស់គ្រហស្ថផង ចាកប្រយោជន៍ជារបស់សមណៈផង គឺជាបុគ្គលមានចំណែកអាក្រក់ រមែងខ្ចាត់ខ្ចាយរោយរាយ ហើយមានការវិនាសទៅ ដូចជាអុសដុតខ្មោច[១] ។

សីល សមាធិ និងបញ្ញា ទាំងអម្បាលនោះដែលបុគ្គលណាបានអប់រំល្អហើយ បុគ្គលនោះ ក៏បានឈានកន្លងនូវវិស័យនៃមារ រមែងរុងរឿងដូចជាព្រះអាទិត្យ ។

១_អុសដុតខ្មោចនោះ ត្រូវភ្លើងឆេះទាំងពីរខាង ត្រង់កណ្តាលប្រឡាក់ លាមកទៀត ។

## ៤០~ ខគ្គវិសាណសុត្តំ ៥៤/១៤-១៦

វំសោ វិសាលោ វ យថា វិសត្តោ
បុត្តេសុ ទារេសុ ច យា អបេក្ខា
វំសាកឡីរោវ អសជ្ជមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
មិគោ អរញ្ញម្ហិ យថា អពន្ធោ
យេនិច្ឆកំ គច្ឆតិ គោចរាយ
វិញ្ញូ នរោ សេរិតំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
នោ ចេ លភេថ និបកំ សហាយំ
សទ្ធឹចរំ សាធុវិហារិ ធីរំ
រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។





## ៤០~ ខគ្គវិសាណសូត្រ បិដក ៥៤,ទំព័រ ១៤-១៦

សេចក្ដីស្រឡាញ់ចំពោះកូននិងប្រពន្ធ ដូចឫស្សីដែលបែកគុម្ព ចាក់កណ្ដាញ់ ។ បុគ្គលកាលមិនជាប់ជំពាក់ ដូចជាទំពាំងឫស្សី គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

ម្រឹគក្នុងព្រៃ ជាសត្វមិនជាប់ចំណង ទៅរកចំណីតាមចំណង់ចិត្តបាន យ៉ាងណាមិញ វិញ្ញូជនក៏មានការសម្លឹងនូវសេរីភាព យ៉ាងនោះដែរ គប្បីត្រាច់ទៅតែម្នាក់ឯងដូចកុយរមាស ។

បើរកអ្នកប្រាជ្ញ ដែលមានធម៌ជាគ្រឿងនៅ ដោយប្រពៃ មានប្រាជ្ញាខ្ជាប់ខ្ជួនមកជាសម្លាញ់ ត្រាច់ទៅជាមួយគ្នាមិនបានទេ បុគ្គលគប្បីត្រាច់ទៅតែម្នាក់ឯង ដូចព្រះរាជាលះបង់នូវដែនដែលព្រះអង្គឈ្នះហើយ[១] ឬដូចដំរីឈ្មោះមាតង្គៈ លះបង់ហ្វូងត្រាច់ទៅក្នុងព្រៃ ដូច្នោះដែរ។

---

១-ដែននោះនាំមកនូវភយន្តរាយ ។ អដ្ឋកថា ។

## ៤១~ កសិភារទ្វាជសុត្តំ ៥៤/២៧-២៨

សទ្ធា ពីជំ តបោ វុដ្ឋិ  បញ្ញា មេ យុគនង្គលំ
ហិរី ឦសា មនោ យោត្តំ  សតិ មេ ផាលបាចនំ។
កាយគុត្តោ វចីគុត្តោ  អាហារេ ឧទរេ យតោ
សច្ចំ ករោមិ និទ្ទានំ  សោរច្ចម្មេ បមោចនំ ។

វីរិយំ មេ ធុរធោរយ្ហំ  យោគក្ខេមាធិវាហនំ
គច្ឆតិ អនិវត្តន្តំ  យត្ថ គន្ត្វា ន សោចតិ។
ឯវំ មេសា កសិ កដ្ឋា  សា ហោតិ អមតប្ផលា
ឯតំ កសឹ កសិត្វាន  សព្វទុក្ខា បមុច្ចតីតិ ។





## ៤១~ កសិភារទ្វាជសូត្រ បិដក ៥៤,ទំ.២៧-២៨

តថាគត មានសទ្ធាជាពូជ មានតបៈជាភ្លៀង មានបញ្ញាជានឹមនិងនង្គ័ល តថាគតមានហិរិជាចន្ទោល មានចិត្តជាខ្សែ មានសតិជាផាលនិងជន្លួញ ។

តថាគត គ្រប់គ្រងកាយ គ្រប់គ្រងវាចា សង្រួមអាហារក្នុងផ្ទៃ ធ្វើការជម្រះស្មៅគឺកិលេសដោយសច្ចៈ តថាគតមានការស្ងប់ស្ងៀម ជាគ្រឿងឈប់សម្រាក ។

វីរិយៈរបស់តថាគត ជាគ្រឿងនាំទៅ នូវធុរៈជាហេតុនាំឱ្យបាននូវព្រះនិព្វានដ៏ក្សេមចាកយោគៈ គឺជាដំណើរទៅកាន់ទីដែលមិនសោកសៅ ជាទីទៅហើយមិនត្រឡប់មករកទុក្ខវិញឡើយ ។

ស្រែដែលតថាគតភ្ជួរហើយយ៉ាងនេះ រមែងឱ្យផលជាអមតៈ បុគ្គលភ្ជួរស្រែបែបនោះ ទើបរួចចាកទុក្ខទាំងពួង ។

## ៤២~មុនិ. វង្គីសសុត្តំ ៥៤/៦៩-៧០-១១២

ឯកំ ចរន្តំ មុនិ អប្បមត្តំ
និន្ទាបសំសាសុ អវេធមានំ
សីហំវ សទ្ទេសុ អសន្តសន្តំ
វាតំវ ជាលម្ហិ អសជ្ជមានំ
បទុមំវ តោយេន អលិម្បមានំ
នេតារមញ្ញេសមនញ្ញនេយ្យំ
តំ វាបិ ធីរា មុនិ វេទយន្តិ ។
នោ ចេ ហិ ជាតុ បុរិសោ កិលេសេ
វាតោ យថា អព្ភឃនំ វិហានេ
តមោវស្ស និវុតោ សព្វលោកោ
ន ជោតិមន្តោបិ នរា តបេយ្យុំ ។





## ៤២~មុនិ. វង្គីសសូត្រ បិដក ៥៤,ទំ.៦៩-៧០-១១២

អ្នកប្រាជ្ញទាំងឡាយ ដឹងច្បាស់នូវបុគ្គលនោះថា ជាមុនី គឺជាបុគ្គលឯកត្រាច់ទៅ ប្រកបដោយមោនេយ្យ-ធម៌ មិនប្រមាទ មិនញាប់ញ័រព្រោះនិន្ទានិងសរសើរ ដូចសត្វសីហៈមិនតក់ស្លុតនឹងសំឡេង ។ មិនជាប់ក្នុងសំ-ណាញ់គឺតណ្ហានិងទិដ្ឋិ ដូចខ្យល់មិនជាប់នឹងសំណាញ់ដែរ។ មិនស្អិតជាប់នឹងលោក ដូចជាផ្កាឈូកមិនជាប់សើមដោយទឹក ។ ជាអ្នកដឹកនាំគេ និងជាបុគ្គលដែលមិនមានគេដឹកនាំ (បានដល់ព្រះសម្មាសម្ពុទ្ធ) ។

បើព្រះសម្មាសម្ពុទ្ធ មិនសម្តែងធម៌ឱ្យជាប្រយោជន៍ដល់ការលះបង់នូវកិលេស ឱ្យដូចជាខ្យល់កម្ចាត់នូវពពកទេ សត្វលោកទាំងអស់ ដែលត្រូវមោហៈរួបរឹតហើយ ក៏ទៅជាងងឹតសូន្យ សូម្បីតែពួកមនុស្សដែលមានពន្លឺ (អម្បាលព្រះសារីបុត្រ) ក៏មិនគប្បីភ្លឺច្បាស់ទៅបានដែរ ។

## ៤៣. បារាយនវគ្គស្ស ៥៤/៣៤៨-៣៦៧

អច្ចិ យថា វាតវេគេន ខិត្តំ
អត្ថំ បលេតិ ន ឧបេតិ សង្ខំ
ឯវំ មុនី នាមកាយា វិមុត្តោ
អត្ថំ បលេតិ ន ឧបេតិ សង្ខំ ។

ទិជោ យថា កុព្ពនកំ បហាយ
ពហុប្ផលំ កាននំ អាវសេយ្យ
ឯវម្បហំ(១) អប្បទស្សេ បហាយ
មហោទធឹ ហំសរិវជ្ឈបត្តោ ។

១.ឯវមាហំ ៦៨/១៣៤





## ៤៣. បារាយនវគ្គ បិដក ៥៤,ទំព័រ ៣៤៨-៣៦៧

(ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧបសីវៈ) អណ្តាតភ្លើង ដែលត្រូវកម្លាំងខ្យល់បក់ផាត់ហើយ រមែងដល់នូវការរលត់ មិនដល់នូវការរាប់ (ថាទៅក្នុងទីណា) យ៉ាងណាមិញ មុនីរួចស្រឡះហើយចាកនាមកាយ រមែងដល់នូវការរលត់ មិនដល់នូវការរាប់ (ថាទៅក្នុងទីណា) ក៏យ៉ាងនោះដែរ ។

( ព្រះបិង្គិយត្ថេរពោលថា ) បក្សីលះបង់ព្រៃតូច ( មានផ្លែតិច ) មកនៅអាស្រ័យនឹងព្រៃធំ មានផ្លែច្រើន ដូចម្តេចមិញ ខ្ញុំលះបង់នូវបុគ្គលទាំងឡាយ ដែលមានការឃើញតិច (មកជួបប្រសព្វនឹងព្រះពុទ្ធដែលទ្រង់មានប្រាជ្ញាច្រើន) ដូចសត្វហង្សបានជួបប្រសព្វនូវស្រះ ដែលមានទឹកច្រើន ដូច្នោះឯង ។

## ៤៤_បឋមោ ទីបង្ករពុទ្ធវំសោ ៧៧/២៦

យថាបិ ជជ្ជរំ នាវំ     បលុត្តំ ឧទកគាហិនី
សាមិកា ឆឌ្ឌយិត្វាន     អនបេក្ខា អនត្ថិកា ។
ឯវមេវាហំ ឥមំ កាយំ   នវច្ឆិទ្ទំ ធុវស្សវំ
ឆឌ្ឌយិត្វាន គច្ឆិស្សំ     ជិណ្ណនាវំវ សាមិកា ។

យថា បុរិសោ ចោរេហិ គច្ឆន្តោ ភណ្ឌមាទិយ
ភណ្ឌច្ឆេទភយំ ទិស្វា     ឆឌ្ឌយិត្វាន គច្ឆតិ ។
ឯវមេវ អយំ កាយោ     មហាចោរសមោ វិយ
បហាយិមំ គមិស្សាមិ     កុសលច្ឆេទនា ភយា ។





## ៤៤_ ទីបង្ករពុទ្ធវង្ស ទី ១ បិដក ៧៧,ទំព័រ ២៦

ម្ចាស់ទូកទាំងឡាយ តែងលះបង់ទូកចាស់ ដែលពុកផុយលេចចូលទឹក ឥតមានអាឡោះអាល័យ ឥតត្រូវការវិញ យ៉ាងណាមិញ អាត្មាអញនឹងលះបង់នូវកាយនេះ ដែលមានរន្ធ ៩ ហូរជានិច្ច ហើយចេញទៅ ដូចជាម្ចាស់ទូកលះចោលទូកចាស់ យ៉ាងនោះឯង ។

បុរស កាលដើរ ទៅជាមួយនឹងពួកចោរ យកទ្រព្យជាប់ទៅផង ឃើញភ័យអំពីការខូចខាតទ្រព្យ ក៏លះបង់ហើយដើរទៅ យ៉ាងណា កាយនេះ ក៏មានឧបមាស្មើដោយមហាចោរ អាត្មាអញនឹង លះបង់កាយនេះចេញព្រោះខ្លាចខូចខាតកុសលធម៌ យ៉ាងនោះដែរ ។

## ៤៥~បឋមោ ទីបង្ករពុទ្ធវំសោ ៧៧/៤២-៤៣

យថាបិ កុម្ភោ សម្បុណ្ណោ យស្ស កស្សចិ អធោកតោ
វមតេ ឧទកំ និស្សេសំ ន តត្ថ បរិរក្ខតិ ។
តថេវ យាចកេ ទិស្វា ហីនមុក្កដ្ឋមជ្ឈិមេ
ទទាហិ ទានំ និស្សេសំ កុម្ភោ វិយ អធោកតោ។

យថាបិ ចាមរី វាលំ កិស្មិញ្ចិ បដិលគ្គិតំ
ឧបេតិ មរណំ តត្ថ ន វិកោបេតិ វាលធិំ។
តថេវ ចតូសុ ភូមីសុ សីលានិ បរិបូរយ
បរិរក្ខ សព្វទា សីលំ ចាមរី វិយ វាលធិំ ។





## ៤៥~ ទីបង្ករពុទ្ធវង្ស ទី ១ បិដក ៧៧,ទំ.៤២-៤៣

ក្អម ដែលមានទឹកពេញ បុគ្គលណាមួយ ផ្កាប់ចុះ ចាក់មិនឱ្យសល់ ទឹកក៏មិនដក់នៅក្នុងក្អមនោះ យ៉ាងណា អ្នកបើ ឃើញពួកស្មូមមក ទោះថោកទាប ខ្ពង់ខ្ពស់ ឬ មធ្យម ចូរឱ្យទាន កុំឱ្យសេសសល់ ឱ្យដូចជាក្អមដែលគេផ្កាប់ យ៉ាងនោះឯង ។

សត្វចាមរី ( កាលឃើញ ) រោមកន្ទុយជំពាក់នឹងរបស់អ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្តាច់កន្ទុយចោលឡើយ យ៉ាងណាមិញ អ្នកចូរបំពេញនូវសីលទាំងឡាយក្នុងភូមិទាំង ៤ ចូររក្សាសីលសព្វកាល ឱ្យដូចជាសត្វចាមរីរក្សានូវរោមកន្ទុយ យ៉ាងនោះចុះ ។

## ៤៦_បឋមោ ទីបង្ករពុទ្ធវំសោ ៧៧/៤៤

យថា អន្ទុឃរេ បុរិសោ ចិរំ វុដ្ឋោ ទុក្ខទ្ទិតោ
ន តត្ថ រាគំ អភិជនេតិ មុត្តឹយេវ គវេសតិ ។
តថេវ ត្វំ សព្វភវេ បស្ស អន្ទុឃរេ វិយ
នេក្ខម្មាភិមុខោ ហោហិ ភវតោ បរិមុត្តិយា ។

យថាបិ ភិក្ខុ ភិក្ខន្តោ ហីនមុក្កដ្ឋមជ្ឈិមេ
កុលានិ ន វិវជ្ជន្តោ ឯវំ លភតិ យាបនំ ។
តថេវ ត្វំ សព្វកាលំ បរិបុច្ឆន្តោ ពុធំ ជនំ
បញ្ញាបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ។





## ៩៦_ ទីបង្ករពុទ្ធវង្ស ទី ១ បិដក ៧៧,ទំព័រ ៤៤

បុរស កាលជាប់នៅក្នុងគុក អស់កាលយូរ ត្រូវសេចក្ដីទុក្ខបៀតបៀនហើយ រមែងមិនញុំាងសេចក្ដីត្រេកអរឱ្យកើតឡើងក្នុងគុកនោះទេ រមែងស្វែងរកការរួច (ចាកគុកនោះ) យ៉ាងណា អ្នកចូរឃើញនូវភពទាំងអស់ដូចជាគុកចុះ ចូរបែរមុខទៅរកនេក្ខម្មៈ ដើម្បីរួចចាកភពក៏យ៉ាងនោះដែរ ។

ភិក្ខុ កាលប្រព្រឹត្តបិណ្ឌបាត មិនវំលងនូវត្រកូលទាំងឡាយ ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម រមែងបានចង្ហាន់ល្មមញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ យ៉ាងណា អ្នកបើសាកសួរអ្នកប្រាជ្ញសព្វកាល នឹងដល់នូវបញ្ញាបារមី ហើយបានសម្រេចសម្ពោធិញ្ញាណមិនខាន ក៏យ៉ាងនោះដែរ។

## ៤៧_បឋមោ ទីបង្ករពុទ្ធវំសោ ៧៧/៤៥-៤៦

យថាបិ សីហោ មិគរាជា និសជ្ជដ្ឋានចង្កមេ
អលីនវីរិយោ ហោតិ បគ្គហិតមនោ សទា ។
តថេវ ត្វំ សព្វភវេ បគ្គណ្ហ វីរិយំ ទឡ្ហំ
វីរិយបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ។

យថាបិ បឋវី នាម សុចីបិ អសុចីបិ ច
សព្វំ សហតិ និក្ខេបំ ន ករោតិ បដិឃទ្ទយំ។
តថេវ ត្វំបិ សព្វេសំ សម្មានាវមានក្ខមោ
ខន្តិបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ។





## ៤៧_ ទីបង្ករពុទ្ធវង្ស ទី ១ បិដក ៧៧,ទំ.៤៥-៤៦

សត្វសីហៈ ជាស្តេចម្រឹគ មានព្យាយាមមិនរួញរា មានចិត្តផ្គូផ្គងសព្វកាល ក្នុងការអង្គុយ ឈរ ដើរយ៉ាងណា អ្នកគួរផ្គូផ្គងព្យាយាមឱ្យមាំមួន ក្នុងភពទាំងពួង យ៉ាងនោះចុះ លុះដល់នូវវីរិយបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ។

ធម្មតាផែនដី រមែងអត់ទ្រាំចំពោះវត្ថុទាំងពួង ទោះស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ រមែងមិនធ្វើនូវសេចក្តីថ្នាំងថ្នាក់ និងសេចក្តីត្រេកអរឡើយ យ៉ាងណា អ្នកក៏គួរអត់ទ្រាំនូវការរាប់អាន និងការមើលងាយ របស់ពួកជនទាំងពួង ក៏យ៉ាងនោះដែរ លុះដល់នូវខន្តិបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។

## ៤៨-បឋមោ ទីបង្ករពុទ្ធវំសោ ៧៧/៤៧-៤៨

យថាបិ ឱសធិ នាម តុលាភូតា សទេវកេ
សមយេ ឧតុវស្សេ វា ន វោក្កមតិ វីថិតោ ។
តថេវ ត្វំបិ សច្ចេសុ មា វោក្កមសិ វីថិតោ
សច្ចបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ។

យថាបិ បព្វតោ សេលោ អចលោ សុបតិដ្ឋិតោ
ន កម្បតិ ភុសវាតេហិ សកដ្ឋានេវ តិដ្ឋតិ ។
តថេវ ត្វំ អធិដ្ឋានេ សព្វទា អចលោ ភវ
អធិដ្ឋានបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ។





## ៤៨- ទីបង្ករពុទ្ធវង្ស ទី ១ បិដក ៧៧,ទំ.៤៧-៤៨

ធម្មតាផ្កាយព្រឹក ជាជញ្ជីងរបស់លោក ព្រមទាំងទេវលោក រមែងមិនឃ្លាតចាកផ្លូវ ក្នុងរដូវភ្លៀង ឬហេមន្តរដូវឡើយ យ៉ាងណា ។ អ្នកកុំឃ្លាតចាកផ្លូវនៃសច្ចៈទាំងឡាយ ក៏យ៉ាងនោះដែរ លុះដល់នូវសច្ចបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ។

ភ្នំថ្ម ឥតកម្រើក តាំងនៅស៊ប់មិនរញ្ជួយដោយខ្យល់ដ៏ខ្លាំងក្លា រមែងតាំងនៅក្នុងទីរបស់ខ្លួនដដែល យ៉ាងណា អ្នកចូរកុំកម្រើក ក្នុងអធិដ្ឋានបារមី សព្វកាល ក៏យ៉ាងនោះដែរ លុះដល់នូវអធិដ្ឋានបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។

## ៤៩_បឋមោ ទីបង្ករពុទ្ធវំសោ ៧៧/៤៩

យថាបិ ឧទកំ នាម      កល្យាណេ បាបកេ ជនេ
សមំ ផរតិ សីតេន      បវាហេតិ រជោមលំ ។
តថេវ ត្វំ ហិតាហិតេ      សមំ មេត្តាយ ភាវយ
មេត្តាបារមិតំ គន្ត្វា      សម្ពោធឹ បាបុណិស្សសិ ។

យថាបិ បឋវី នាម      និក្ខិត្តំ អសុចឹ សុចឹ
ឧបេក្ខតិ ឧភោបេតេ      កោធានុនយវជ្ជិតា ។
តថេវ ត្វំ សុខទុក្ខេ      តុលាភូតោ សទា ភវ
ឧបេក្ខាបារមិតំ គន្ត្វា      សម្ពោធឹ បាបុណិស្សសិ ។





## ៤៩_ ទីបង្ករពុទ្ធវង្ស ទី ១ បិដក ៧៧,ទំព័រ ៤៩

ធម្មតាទឹក រមែងផ្សព្វផ្សាយត្រជាក់ស្មើ ចំពោះជនទាំងល្អ ទាំងអាក្រក់ រមែងកម្ចាត់បង់នូវធូលី និងមន្ទិលយ៉ាងណា ។ អ្នកចូរចម្រើនមេត្តាឱ្យស្មើ ចំពោះមិត្តនិងសត្រូវ ក៏យ៉ាងនោះដែរ លុះដល់នូវមេត្តាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ។

ធម្មតាផែនដី តែងព្រងើយកន្តើយ ចំពោះវត្ថុមិនស្អាតក្តី ស្អាតក្តី ដែលគេដាក់ចុះហើយ តែងវៀរចាកសេចក្តីក្រោធ និងសេចក្តីត្រេកអរ ចំពោះវត្ថុទាំងពីរនោះយ៉ាងណា អ្នកចូរធ្វើខ្លួនឱ្យដូចជាជញ្ជីង ចំពោះសុខ និងទុក្ខ សព្វកាល ក៏យ៉ាងនោះដែរ លុះដល់នូវឧបេក្ខាបារមីហើយ នឹងបានសម្រេច សម្ពោធិញ្ញាណពុំខាន ។

ចប់

# ព្រៃឫស្សី

សូរសព្ទសាសងសរសើរសង្សារ ចង់ចូលចរចាចាប់ចិត្តចាំចង
បបោសបីបាច់បើបានបៀតបង ដណ្ដឹងដប់ដងដុនដាបដិតដាម ។
លួចលាក់លលេងលិចលង់លបលោត រហេតរហួតរហេមរហាម
រសាប់រសល់រសេមរសាម ដឹងដល់ដៀមដាមដោះដៃដេញដោល ។
បែកបាក់បាត់បង់បបួលបែរបន់ តាមតែតូចតន់តឹងតែងតែលតោល
ចចេសចូលចាប់ចុះចាញ់ចាកចោល បំបរបំបោលបំបែកបំបាក់ ។
ស្នូរស្នេស្នាមស្នាស្នេហ៍ស្នងស្និទ្ធស្នាល អ៊ីអ៊ំអុចអាលអល់អែកអន់អាក់
ថ្លើមថ្លៃថ្លាថ្លែងថ្លោះថ្លោយថ្នាំងថ្នាក់ ប្រឹងប្រែងប្រើប្រាក់ប្រែប្រួលគូព្រេង ។
រឿងរ៉ាវរៀបរាប់ចប់ឥតខ្លឹមសារ រឿងរ៉ាវស្នេហារិលវល់វង្វេង
បើរស់អត់សីលគ្មានធម៌ទប់ជ្រែង ទោះអាយុវែងវែងតែវេលា ។
សែសិបប្រាំបីវយវឌ្ឍនាការ ប្រាំងទល់វស្សាឈើពុំសូវជា
បើស្នេហ៍មិនស្លាប់យើងបានជួបគ្នា ស្ដាប់ធម៌សន្ទនាចម្រើនបារមី ។
ចូលសែប្រាំបួនជួនជួបគុណគាប់ បុណ្យធំជាទ្រព្យជូនខួបឆ្នាំថ្មី
នៅវត្តវេឡុវន័ហៅព្រៃឫស្សី ឆ្លងព្រះចេតិយឆ្លងខ្លោងទ្វារផ្លូវ ។



ខ្ញុំកើតមិនទាន់វេឡុវន័ស្រុកព្រះ តែបានប្រទះវេឡុវន័ឥឡូវ
ចំថ្ងៃកំណើតហើយចែកសៀវភៅ អានឱ្យចប់ទៅហើយទុកឱ្យគង់ ។
ព្រោះការចេះចាំទោះច្រើនឬតិច អាចភ្លាំងភ្លាត់ភ្លេចក្លាយទៅជាល្ងង់
បើមានគម្ពីរទុកជួយទ្រទ្រង់ បើភ្លេចក៏គង់នៅមានទីអាង ។
សំណល់សំណៅសំណេរសំណព្វ ពេលខ្លះមានភ័ព្វក្លាយជាសំណាង
អ្នកប្រាជ្ញមានក្បួនទុកជាទីអាង រក្សាភ័ស្ដុតាងទុកមិនឱ្យបាត់ ។
ដូចស្ដេចមានទ័ពទុកជាកម្លាំង ពេលមានចោរខ្មាំងទ័ពចេញកម្ចាត់
បណ្ឌិតមានបុណ្យទុកជាសម្បត្តិ អប់រំហ្វឹកហាត់សតិបញ្ញា ។
រីឯធម្មជាតិលើភពផែនដី ភ្លឺដោយរស្មីនៃដួងសុរិយា
សូមឱ្យសព្វសត្វមានចិត្តភ្លឺថ្លា ដោយមានបញ្ញាជាដួងរស្មី ។
ខ្យល់ជំនោរធ្លាក់ត្រជាក់សព្វសាយ ត្រជាក់ផ្លូវកាយនៃជនប្រុសស្រី
សូមឱ្យសព្វសត្វត្រជាក់ហឫទ័យ ដោយទឹកមន្តនៃទឹកចិត្តមេត្តា ។
សូមកុំចាញ់បោករឿងសង្សារវដ្ដ សូមកុំភ្លាំងភ្លាត់ផុងភក់តណ្ហា
សូមផ្ដោះរំលងឆ្លងភពអន្ធការ ផុតវដ្ដសង្សារដល់ត្រើយនិព្វាន ។

ដោយឧបាសក **គុយ សុធន**

## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការងារធម្មទាន

| | |
|---|---|
| ១. ឧបាសក សំរ៉ង វណ្ណៈ | ២. ឧបាសក យន្ត សួន |
| ៣. ឧបាសក គួង លាងផេង | ៤. ឧបាសក មួង យេន |
| ៥. លោកគ្រូ រស់ សូផាត | ៦. ឧបាសក អ៊ិត ប្រាំង |
| ៧. នាង ជា សុណារី | ៨. ឧបាសិកា ប៊ុត ម៉ាលី |
| ៩. ឧបាសក គុយ សុធន | ១០. ឧបាសក វ៉ាន់ ខុនណា |
| ១១. ឧបាសក សោម រតនៈ | ១២. ឧបាសក ជឹង វ៉េងអ៊ាវ |
| ១៣. ឧបាសក ជឹម ជំនិត | ១៤. ឧបាសក ហាយ ចំរើន |
| ១៥. ឧបាសិកា ហាយ ច័ន្ទធរី | ១៦. លោកគ្រូ ជូ ប៊ុនយូ |
| ១៧. ឧបាសក ង៉ូវ គា | ១៨. ឧបាសក ម៉ៅ ផុន |
| ១៩. ឧបាសិកា ហួនចាន់បូជា | ២០.ឧបាសិកា ស្រី បូរ៉ាន់ |



## រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
## ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

១- ឧ.ស. យូស៊ាង ងួនលី និង ឧ.សិ. លីម ឃីម ................. ស.រ.អ.

២- ឧ.ស. ឆាយ អ៊ីវស៊ាង និង ឧ.សិ.ហុង គីមសែ ............. ស.រ.អ.

៣- ឧ.ស. ឆាយអ៊ីវ ស្រេងលីម និង ឧ.សិ.ហួត ឃីម.......... ស.រ.អ.

៤- ឧ.ស. ហៃ ប៊ុនណារិន និង ឧ.សិ.អោង ស៊ីថាន់ ........... ស.រ.អ.

៥- ឧ.ស. វង់ ម៉ៅ និង ឧ.សិ.ឆាន់ កាន់ជួង ព្រមទាំងបុត្រ......ស.រ.អ.

៦- ឧ.សិ. ឆាន់ ហៃគីង ព្រមទាំងបុត្រ និង ចៅ ................ ស.រ.អ.

៧- ឧ.សិ.ប៊ិត ថងខាំ + ឧ.សិ.សាន ផល្លីន ព្រមទាំងបុត្រ ...... ស.រ.អ.

៨- ឧ.សិ. ស៊ីវ យក់លុយ ............................................. ស.រ.អ.

៩- ឧ.ស. អ៊ុត ឆៃវ៉ាន និង ឧ.សិ.ធាន ស៊ុនលី និងបុត្រ........ ស.រ.អ..

១០- ឧ.ស. ប្លោក ងួនថៃ ឧ.សិ.ធាន ត្រលុច និងបុត្រ ..........ស.រ.អ.

១១- ឧបាសិកា អ៊ឹង ស៊ីវន .............................................. ស.រ.អ.

១២- ឧ.ស.សូ ហុកឡុង ឧ.សិ.កាន់ ឈីវហា .......................ស.រ.អ.

១៣- ឧ.ស. អៀង ឆាយ និង ឧ.សិ. អៀ-កេសរ +បុត្រ .........ស.រ.អ.

១៤- លោកតា តាន់ ឈីវហា + លោកយាយ ស៊ូ ចិន្ត្រ ........... ស.រ.អ.

១៥- ឧ.សិ. តែ សាយជូ ព្រមទាំងកូនចៅ ........................... ស.រ.អ.

១៦- ឧ.ស.ជិម អេងស្រ៊ន និង ភរិយា ព្រមទាំងបុត្រ ........... ស.រ.អ.

១៧- ពុទ្ធបរិស័ទ ចាន់ នារីសុខ និងក្រុមគ្រួសារ ................... ស.រ.អ.

១៨- ឧ.សិ. ម៉ិល យ៉ែម .................................................... ស.រ.អ.

១៩- ឧ.ស.សាវឿន ឧ.សិ.លាប+ឧ.ស.ហ៊ីស៊ុ ឧ.សិ.អាន ........ ស.រ.អ.

២០- ឧបាសក តាំង ស៊ុនម៉ាប .............................................ស.រ.អ.

២១- លោក ចក់ ឈុន និង អ្នកស្រី វណ្ណារី សុខ .................... ស.រ.អ.

២២- លោកយាយ ពិន សាត ............................................ ស.រ.អ.

២៣- លោក ចាន់ ម៉ល់ និងអ្នកស្រី ជា សុផា ........................ ស.រ.អ.

២៤- ភិក្ខុ ឈម បូ (វិជ្ជាសម្បទា )..................................... ស.រ.អ.

២៥- ឧ.ស. ជា ស៊ុវត្ថានា និង ឧ.សិ.ឃុន សូនីម៉ា .................. ស.រ.អ.

២៦- ឧ.សិ.លី ប៉ូលីនស៊ីមប៉ូ ............................................... ស.រ.អ.

២៧- ឧ.ស.ហាក់ ច័ន្ទសុផល និង ឧ.សិ.វ៉ាង ស៊ីណា+បុត្រ....... ស.រ.អ.

២៨- ឧ.ស.ស៊ុន ដារិន និង ឧ.សិ.ទូច ចន្ទី ............................. ស.រ.អ.

២៩- ឧ.ស.ឡៅ ហោ និង ឧ.សិ.ង៉ោ ស៊ូអេង ....................... ស.រ.អ.

៣០- ឧ.សិ.តាន់ ភិចជូ ព្រមទាំងបុត្រធីតា និងចៅៗ ............. ស.រ.អ.

៣១- ឧ.សិ.ស្រង់ អែ និង ឧ.សិ.ស្រង់ ឡេង ........................ ស.រ.អ.

៣២- ឧ.សិ.ឧត្តមា ពេជ្រ អូន ............................................ ស.រ.អ.

៣៣- ឧ.ស.វ៉ាង សារុំថ និង ឧ.សិ.គង់ ស៊ីណាត +បុត្រ ........... ស.រ.អ.

-១០៣-

៣៤- ភិក្ខុ ឈួម បូ (វត្តពន្លឺពុទ្ធចក្រ លោវែល ) .................. ស.រ.អ.

៣៥- លោក ពេជ្រ សីហា និងអ្នកស្រី ថាប់ សុវត្ថិ ...................ស.រ.អ.

៣៦- ឧ.ស.ប៊ុត ផល និង ភរិយា ...................................... ស.រ.អ.

៣៧- លោកគ្រូធម្មបណ្ឌិត អឿ សៅ ................................. ស.រ.អ.

៣៨- ឧ.ស.ប៊ូ ហោនាង និង ឧ.សិ.អ៊ឹង រីទ្ធារី ព្រមទាំងបុត្រ ... ស.រ.អ.

៣៩- លោក កេត សេរីភ័ត្រ និង អ្នកស្រី ប៉ុល ហត្ថា............... ស.រ.អ.

៤០- ឧ.សិ.ឡុង អ៊ុម ...................................................... ស.រ.អ.

៤១- ឧ.សិ.ច័ន្ទ ប៉ុណ្ណារី......................................................ស.រ.អ.

